# ការសំភាសន៍របស់អ៊ុំស្រី ប៉ាល់ សុឃីម

**ក៖ អ្នកដែលសំភាសន៍ឈ្មោះ ជាង ស៊ីអ៊ាវ ខ៖ អ្នកត្រូវគេសំភាសន៍ឈ្មោះ ប៉ាល់ សុឃីម**

ក៖ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសម្ភាសទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាសទាំងអស់ហ្នឹងត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្តាយហ្នឹងដូនតា ជាពិសេសប្រវត្តិរបស់អ៊ុំទុកអោយកូនហ្នឹងចៅៗរបស់អ៊ុំបានស្គាល់បានដឹងពីប្រវត្តិរបស់អ៊ុំដែរអ៊ុំបានសម្ភាសជាមួយខ្ញុំ ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំពិភាក្សាមួយហ្នឹងទៅក្នុងវេបសាយរបស់សាលាអត់អ៊ុំ ដូចជាខ្ញុំហ្នឹងការសម្ភាសរបស់អ៊ុំមួយហ្នឹងដាក់ក្នុងវេបសាយដើម្បីទុកអោយកូនចៅជំនាន់ក្រោយរបស់អ៊ុំបានស្គាល់បានដឹងចឹងហាសណាស់អ៊ុំ?

ខ៖ ចាំ!

ក៖ បាទអ៊ុំចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី២៦ ខែ៧ឆ្នាំ២០២០?

ខ៖ ចាំ!

ក៖ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិហ្នឹងភូមិអីគេអ៊ុំភូមិឡូតដ្ឋហេស?

ខ៖ ឡូតដ្ឋ។

ក៖ ភូមិឡូតដ្ឋ ឃុំបឹងកុក ស្រុកកំពង់ចាមហេស?

ខ៖ ខេត្តកំពង់ចាម។

ក៖ ស្រុកកំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាមមែនអត់ចឹងសំរាប់អើអ៊ុំឈ្មោះពេញរបស់អ៊ុំទាំងត្រកូលម៉ងឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះប៉ាល់ សុឃីម។

កៈ ប៉ាល់ សុឃីមប៉ោរីមួយក៏ប៉ាល់?

ខៈ ប៉ាល់។

កៈ ប៉ាល់ហោស?

ខៈ ចាំ!

កៈ អ៊ូបាទអ៊ីចុះអ៊ីមានឈ្មោះហៅក្រៅអត់អ៊ី?

ខៈ ឈ្មោះក្រៅឈ្មោះប៉ាល់ឡេន។

កៈ អ៊ូអាហ្នឹងគេហៅលេងណោះអ៊ីណោះ?

ខៈ ចាំហៅឡេន។

កៈ អ៊ូចុះកាលពីក្មេងអីធ្លាប់មានបងប្អូនរឺមួយសាច់ញ្ញាតិឪពុកម្តាយហៅអ៊ីឈ្មោះអីលេងផ្សេងពីហ្នឹងទៀតអត់?

ខៈ អត់មានទេ។

កៈ ចឹងមានតែឈ្មោះ..?

ខៈ ឡេន។

កៈ ប៉ាល់ សុឃីមមួយហ្នឹងហើយឈ្មោះឡេនមួយ?

ខៈ ចាំ!

កៈ អ៊ូបាទចុះអ៊ីសព្វថ្ងៃអ៊ីអាយុប៉ុន្មានទៅអ៊ី?

ខៈ ហុកសិប។

កៈ អ៊ីហុកសិបឆ្នាំចុះអ៊ីកើតនៅថ្ងៃខែឆ្នាំណាអ៊ីចាំទេអ៊ី?

ខៈ អើភ្លេចហើយ!

កៈ ចុះអើឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានក៏អ៊ុំអត់ចាំដែរណោះអ៊ុំណោះ?

ខៈ មានសៀវភៅគ្រួសារអើសៀវភៅនេះចាំ!

កៈ សៀវភៅគ្រួសារ?

ខៈ សៀវភៅគ្រួសារហើយហ្នឹងមានបងយកអោយមើល។

កៈ អ៊ូអត់អីទេអ៊ុំបលអ៊ុំអត់ចាំចុះឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេអ៊ុំ?

ខៈ ឆ្នាំឆ្លូវ។

កៈ អ៊ុំឆ្នាំឆ្លូវហោស?

ខៈ ឆ្នាំឆ្លូវ។

កៈ ចុះស្រុកកំណើតដែរអ៊ុំកើតម៉ងអ៊ុំកើតនៅណានៅស្រុកណា?

ខៈ នៅកោះកំពង់សៀម។

កៈ ប៉ុន្តែភូមិអីគេអ៊ុំនៅហ្នឹង?

ខៈ ភូមិកោះកុក។

កៈ អ៊ូកោះកុកនៅខាងកោះ..?

ខៈ កោះកុក។

កៈ ស្គាលហើយ!

ខៈ កោះរកាកោះប្រាក់នេះ។

កៈ បាទៗស្គាល់?

ខៈ កោះកុក។

កៈ ប៉ុន្តែនៅណុងគេហៅឃុំអីគេអ៊ុំ?

ខ៖ ឃុំកោះទទឹម។

ក៖ ភូមិកោះកុក ឃុំកោះទទឹមស្រុកកំពង់សៀមណោះ?

ខ៖ ចាំ!

ក៖ ប៉ុន្តែឥឡូវដូរស្រុកវិញហើយរឺមួយក៏ម៉េច?

ខ៖ ស្រុកកំពង់សៀមចឹងហើយ ស្រុកឃុំកោះទទឹម។

ក៖ អូ៎!

ខ៖ ភូមិកោះកុក។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាអ៊ុំមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ ចំនួនប្រាំពីរនាក់។

ក៖ ប្រាំពីរនាក់?

ខ៖ ចាំ!

ក៖ ប៉ុន្តែមានស្រីប៉ុន្មានប្រុសប៉ុន្មានអ៊ុំ?

ខ៖ ស្រីប្រាំមួយប្រុសមួយ។

ក៖ អ៊ុំកូនទីប៉ុន្មានទៅ?

ខ៖ ខ្ញុំកូនទីមើលទីមួយទីពីរទីបីទីបួនទីប្រាំហើយទីប្រាំ។

ក៖ អូ៎អ៊ុំកូនទីប្រាំហោស?

ខ៖ ចាំ!

ក៖ ចុះអើចឹងអ៊ុំអាចប្រាប់ថាមានឈ្មោះអីគេខ្លះបងរបស់អ៊ុំហើយហ្នឹងប្អូនរបស់អ៊ុំបានទេ?

ខ៖ ឈ្មោះទីមួយឈ្មោះប៉ាល់ សុខន។

កៈ អ៊ូ!

ខៈ ទីពីរឈ្មោះប៉ាល់អាលែងមើលប៉ាល់សុខេន។

កៈ អ៊ូ!

ខៈ ទីបីប៉ាល់សុខឿន អើមើលទី។

កៈ ទីបួន?

ខៈ ទីបួនខ្ញុំហ្នឹង!

កៈ អ៊ុំទីប្រាំរឺមួយក៏ទីបួនអ៊ុំ?

ខៈ មើលទីមួយប៉ាល់សុខន ទីពីរប៉ាល់សុខេន ទីបីប៉ាល់សុខឿន ទីបួនប៉ាល់ខ្ញុំប៉ាល់សុឃឹម ហៅឡេនហ្នឹងហាស!

កៈ បាទ!

ខៈ ចាំទីបួនទេចឹងហោសទីបួន។

កៈ បាទចុះទីប្រាំអ៊ុំ?

ខៈ ទីប្រាំប៉ាល់សុខុន។

កៈ ទីប្រាំមួយ?

ខៈ ទីប្រាំមួយប៉ាល់ចាន់ថន។

កៈ ដល់ពេលទីប្រាំពីរ?

ខៈ អស់ហើយមើលទីប្រាំពីរអស់ហើយ!

កៈ ចឹងអ៊ុំមានបងប្អូនតែប្រាំមួយនាក់ទេ?

ខៈ ប្រាំមួយចឹងហើយប្រាំមួយនាក់។

កះ អ៎ូបាទអ៊ុំចុះអើប៉ុន្តែបងប្អូនរបស់អ៊ុំនៅរស់សព្វថ្ងៃទាំងអស់គ្នាទេ?

ខះ អត់អស់ទេនៅតែបីនាក់ទេសព្វថ្ងៃហ្នឹងហោស!

កះ ឥឡូវហោស?

ខះ ចា៎ហាសមើលហុច មូវ អ៎ូនៅបួននាក់។

កះ បួននាក់ណេះ?

ខះ ចា៎!

កះ ចុះស្លាប់ទីប៉ុន្មានខ្លះទៅអ៊ុំ?

ខះ ស្លាប់ទីមួយទីពីរស្លាប់ជំនាន់គេរើសធ្វើអាលែងរំដោះហោស!

កះ អ៎ូបាទ!

ខះ ជំនាន់អាលែងនេះហ្នឹង!

កះ គេយកគាត់ទៅសំលាប់រឺ..?

ខះ ទៅធ្វើទាហ៊ានទាំងអស់។

កះ ឬម៉េច?

ខះ អត់ទេៗទៅធ្វើទាហ៊ានទៅទៅចេញទៅចិតប្រាំណុងបាត់ទៅតែម៉ងណុងហាស!

កះ អ៎ូយើងអត់ដឹងដំណឹងពួកគាត់?

ខះ អត់ដឹងដំណឹងទាល់តែថ្ងៃហ្នឹង!

កះ ចឹងយើងគិតថាពួកគាត់ស្លាប់ម៉ង?

ខះ ចា៎កូនទីមួយដឹងថាស្លាប់ស្លាប់នៅភ្នំពេញ។

កះ អ៎ូ!

ខ៖ ឈឺ។

ក៖ ហើយយ៉ាងណាមួយបើសិនជាគាត់នៅរស់កាត់មករកយើងហើយណោះ?

ខ៖ ចាំ!

ក៖ ប៉ុន្តែពួកគាត់ហ្នឹងពេលពួកគាត់ស្លាប់ហ្នឹងពួកគាត់មានគ្រួសារនៅ?

ខ៖ នៅនៅលីវ។

ក៖ នៅ..?

ខ៖ បើបងៗបងគេមានហើយបងបង្អស់ណុងមាន។

ក៖ អូ៎បាទ!

ខ៖ ប្រាក់សុខនណុងមាននៅបានកូនមួយ។

ក៖ បាទអ៊ឺបាទ!

ខ៖ បានដល់ចេញមកកូនហ្នឹងហើយហ្នឹងឪពុកហ្នឹងគេយកវ៉ៃចោលជំនាន់ប៉ុលពតហ្នឹងហាស!

ក៖ ចឹងមានន័យថាគ្រួសារគាត់អត់មានម៉ងចឹងដល់ពេលយកទៅវ៉ៃចោលទាំងអស់ចឹង?

ខ៖ ណុងហើយអត់មានគ្រួសារទេឪឡូវហ្នឹងវ៉ៃចោលនៅសល់តែកូនហើយហ្នឹងប្តីហ្នឹងវ៉ៃចោល បងអ៊ូប៉ាល់សុខនហ្នឹងគាត់ស្លាប់នៅភ្នំពេញហ្នឹងគាត់មានជំងឺទាស់កូនខ្ចីចឹងហាស!

ក៖ អូ៎បាទចុះទីពីរទីពីរគាត់..?

ខ៖ ទីពីរ..។

ក៖ អត់ទាន់មានគ្រួសារទេ?

ខ៖ ហ្នឹងអត់ទាន់មានគ្រួសារគេរើសយកទៅធ្វើទាហ៊ាន។

ក៖ អូ៎ដល់ពេលចូលទីបី?

ខ៖ ទីបីនៅណោះនៅតាកែវនៅខេត្តតាកែវនៅផ្សារសំរោងយោងហោស!

ក៖ អូ៎ស្គាល់ប៉ុន្តែគាត់ធ្វើអីគេនៅណុងអ៊ុំ?

ខ៖ អត់មានធ្វើអីទេ។

ក៖ អូ៎!

ខ៖ អាលែងនៅជាមួយកូន។

ក៖ គាត់មានចៅហើយណោះអ៊ុំណោះ?

ខ៖ មានចៅ។

ក៖ អូ៎បាទអ៊ុំដល់ពេលចូលមកអ៊ុំអ៊ុំក៏នៅជាមួយកូនចៅដែរណោះអ៊ុំណោះ?

ខ៖ នៅជាមួយកូនចៅហ្នឹង!

ក៖ អូ៎ចុះទីប្រាំអ៊ុំ?

ខ៖ ទីប្រាំណោះនៅពាមជីកង។

ក៖ ប៉ុន្តែគាត់ធ្វើអីគេអ៊ុំ?

ខ៖ ធ្វើស្រែធ្វើចំការហ្នឹង!

ក៖ អូ៎គាត់ក៏មានកូនចៅទៀតដែរ?

ខ៖ ក៏មានកូនចៅ។

ក៖ ចុះពៅកូនពៅទីប្រាំមួយ?

ខ៖ ពៅណោះទៅនៅណោះដល់ជំនាន់ប៉ុលពតអូ៎ជំនាន់ទាហ៊ានចឹងហើយ!

ក៖ បាទអ៊ុំ!

ខ៖ ជំនាន់គេចាប់ទាហ៊ានហោស!

កៈ បាទអ៊ុំបាទ!

ខៈ ទៅឡើងដេកលើដំបូលផ្ទះឡើងពេលអីគេមកចាប់ទៅជូនណាជីករណ្ដៅជីករណ្ដៅទៅដាក់ទ្រុងគោទៅដាក់អាលែងដល់ពេលមើលគេមកចាប់ចូលក្នុងរណ្ដៅទៅដាក់កំប្លោកពីលើទៅ ដល់ពេលទ្រាំអត់បានឪពុកមាអោយទៅអីទៅនៅៗអលែងស្អីទេទៅនៅ..។

កៈ អត់អីទេបើអ៊ុំអត់ចាំ?

ខៈ ទៅនៅស្អី។

កៈ អ៊ូអត់ចាំអត់អីទេ?

ខៈ ទៅនៅណុងទៅទៅអាលែងទៅនៅធ្វើឡូទៅនៅធ្វើស្អីធ្វូឡូចឹងឡូថ្នាំឡូថ្នាំប៉េងអាននៅនេះហ្នឹងរួចដល់ពេលនេះទៅយកគ្រួសារនៅណុងដល់ពេលឥឡូវមានកូនប៉ុន្មានបីបួននាក់ ប៉ុនដល់ទៅនៅអឺស្រុកគេហៅស្អីទេនេះបានកូនប្រាំបួននាក់ឧត្ដរមានជ័យទៅនៅឧត្ដរមានជ័យណុងហាសឥឡូវណុងហាស!

កៈ នៅបានឆ្ងាយណោះអ៊ុំ?

ខៈ នៅបានឆ្ងាយនាំគ្នាទៅធ្វើកម្មករទៅថៃទៅអីហោស!

កៈ អ៊ូ!

ខៈ ទៅរកស៊ីនៅថៃ។

កៈ អាហ្នឹងកូនពៅ?

ខៈ អាហ្នឹងកូនពៅហើយប្រុសមានតែមួយហ្នឹង!

កៈ អ៊ូបាទអ៊ុំ!

ខៈ ចាំ!

កៈ ចុះអ៊ុំគិតថាអ៊ុំធ្លាប់មានអនុស្សាវរីយ៍ដូចជាធ្លាប់ចងចាំអីខ្លះចឹងជាមួយបងៗរឺប្អូនអ៊ុំកាលនៅតូចៗហាស?

ខ៖ ចាំ!

ក៖ ធ្លាប់ធ្វើស្រែធ្វើចំការរឺមួយក៏ជំនាន់ប៉ុលពតធ្លាប់មានជាអនុស្សាវរីយ៍អីអត់អ៊ុំ?

ខ៖ នៅដូចធ្លាប់នៅជាមួយបងប្អូនអីអត់មានអីទេខ្ញុំឪពុកម្តាយស្លាប់ចោលនៅតូចៗ។

ក៖ អូ៎ចឹងមានន័យថាពេលពួកគាត់ស្លាប់ពីមុនប៉ុលពតទៀតណេះ?

ខ៖ ជំនាន់ប៉ុលពតហ្នឹងហាសស្លាប់ហាស!

ក៖ អូ៎!

ខ៖ ស្លាប់ឪពុកបានអូ៎ស្លាប់ម្តាយម្តាយអាសន្នរោគហោស!

ក៖ អូ៎!

ខ៖ ទៅនៅទួលស្រែស៊ីពោតក្រហមអូ៎ពោតស្ងោរប៉ុន្មានចែករបបពីរបីដល់ពេលគាត់ពិសារទៅឈឺចុះងាចម៍ទៅគេយកទៅនៅអង្គុញដីហោសធ្វើនៅអង្គុញដីស្លាប់នៅអង្គុញដីណុងទៅ។

ក៖ អូ៎បាទ!

ខ៖ រួចទៅបានមួយខែទៀតឪពុកនៅនៅឈឺនៅកោះណុងនៅកោះហ្នឹងគាត់បានមួយទៀតស្លាប់ឪពុកទៀតទៅកំព្រារាល់ថ្ងៃហ្នឹង!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចឹងមានន័យថាអើបងប្អូនអ៊ុំមកទាល់ឥឡូវពួកគាត់នៅបែកគ្នាទាំងអស់?

ខ៖ បែកគ្នាទាំងអស់។

ក៖ ដោយសារមានកូនចៅនៅរៀងខ្លួនណេះ?

ខ៖ ចាំ!

ក៖ ចឹងមានតែកូនពៅទេដែរនៅឆ្ងាយពីគេណេះអ៊ុំ?

ខ៖ ចាំនៅកូនពៅនៅឆ្ងាយពីគេ។

ក៖ ត្រូវហើយបងប្អូននៅតែកំពង់ចាមប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ នៅកំពង់ចាមនៅតែម្នាក់ឯងហ្នឹងខ្ញុំ។

ក៖ ចុះពួកគាត់នៅកន្លែងផ្សេង..?

ខ៖ នៅ..។

ក៖ នៅតាកែវ?

ខ៖ នៅពាមជីកងមួយ។

ក៖ អូ៎!

ខ៖ ពាមជីកងហើយនៅកំពង់ចាមប៉ុន្មានអើកំពង់ចាមពីរនាក់រួចនៅ..។

ក៖ អូ៎បាទអ៊ុំចុះអើសំរាប់ឪពុករបស់អ៊ុំឈ្មោះអីគេអ៊ុំ?

ខ៖ ឪពុកឈ្មោះមើលប៉ាល់ពន មើលប៉ាល់ពន។

ក៖ បាទអ៊ុំ!

ខ៖ ប៉ាល់ចឹងហើយប៉ាល់លួញដែរណោង។

ក៖ ប៉ាល់អីប៉ាល់ពន?

ខ៖ ហ្នឹងហើយប្អូនគាត់ឈ្មោះប៉ាល់លួញ។

ក៖ អូ៎ចុះអើ..!

ខ៖ គាត់បងប្អូនគាត់មានតែបីនាក់។

ក៖ បាទអ៊ុំចុះអើម្ដាយរបស់អ៊ុំមានឈ្មោះអីទៅអ៊ុំ?

ខ៖ នងយីន។

ក៖ នងយីន?

ខ៖ ចា៎!

ក៖ អ៎ូបាទអ៊ុំចុះអើឪពុករបស់អ៊ុំគាត់អ្នកស្រុកនៅណាអ៊ុំ?

ខ៖ អ្នកស្រុកនៅធ្លាប់ដឹងមកនៅកោះកុកណុងម៉ង។

ក៖ អ៎ូ!

ខ៖ ធ្លាប់ដឹងក្តីមក។

ក៖ ម្តាយអ៊ុំគាត់នៅណុង?

ខ៖ ចា៎នៅណុងប៉ុនគាត់នៅគាត់នៅខាងផ្តង់ប៉ុនថានៅជាមួយគ្នាទៅបានជិតគ្នាគ្រាន់ឆ្លងទន្លេ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចា៎!

ក៖ ចុះឪពុករបស់អ៊ុំកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត ចិញ្ចឹមកូនចៅអ៊ុំ?

ខ៖ អត់មានធ្វើអីទេធ្វើដូចថាធ្វើស្រែធ្វើចំការហ្នឹងដឹកគរខែដឹកគរដឹកគរអោយម៉ូយចឹង។

ក៖ អ៎ូ!

ខ៖ រកស៊ីធ្វើស្រែធ្វើចំការហ្នឹង!

ក៖ អ៎ូបាទអ៊ុំប៉ុន្តែគាត់ជាមនុស្សបែបណាកាចរឺមួយក៏ស្លូតអ៊ុំ?

ខ៖ គាត់អត់អ្នកកាចទេគាត់ម៉ាធម្មតា។

ក៖ អ៎ូគាត់ស្លូតដែរ?

ខ៖ ប៉ុនកូនៗខ្លាចគាត់គាត់អត់សូវមាត់ទេ។

ក៖ ចឹងហោសអ៊ុំ?

ខ៖ ចា៎!

ក៖ ចុះម្ដាយរបស់អ៊ុំធ្វើការសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមក្រុមគ្រួសារ?

ខ៖ ចិញ្ចឹមជីវិតហ្នឹងគាត់មានធ្វើអីធ្វើស្រែចំការហ្នឹង!

ក៖ អូ៎ប៉ុន្តែស្លូតដែរណោះអ៊ុំ?

ខ៖ ស្លូតទេ។

ក៖ អូ៎បាទចុះអើអ៊ុំធ្លាប់មានអនុស្សាវរីយ៍រឺមួយក៏អ៊ុំធ្លាប់មានចងចាំថាធ្លាប់ធ្វើអីគេខ្លះជាមួយឪពុកម្ដាយអត់អ៊ុំ?

ខ៖ ខ្ញុំហោស?

ក៖ បាទ!

ខ៖ កាលជំនាន់ណុងមាននៅជាមួយឪពុកម្ដាយមានធ្វើអីទេមានតែរៀនហើយហ្នឹងដូចថាជួយរកស្មៅគោស្មៅអីគាត់ចឹងទៅណាស់។

ក៖ អូ៎បាទអ៊ុំ!

ខ៖ គាត់ទៅធ្វើការទៅរកស្មៅគោជាមួយម្ដាយជាមួយគាត់ទៅ។

ក៖ អូ៎ប៉ុន្តែដូចជាអ៊ុំធ្លាប់ធ្វើស្រែធ្វើអីជាមួយពួកគាត់ដែរណោះអ៊ុំណោះ?

ខ៖ ខ្ញុំ..។

ក៖ ចំការ..?

ខ៖ ដល់ពេលគាត់ស្លាប់បាត់ទៅខ្ញុំដឹងក្ដីធំទៅខ្ញុំធ្វើស្រែធ្វើចំការហ្នឹង!

ក៖ អូ៎!

ខ៖ ធ្វើចំការធ្វើស្រែតែប៉ុណ្ណឹង!

ក៖ បាទអ៊ុំចុះអ៊ុំគិតថាឪពុករបស់អ៊ុំគាត់ធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំអត់អ៊ុំ?

ខ៖ ចាំ!

ក៖ ឪពុករបស់អ៊ុំហាសគាត់ធ្លាប់បង្រៀនពីជំនាញអីមួយទៅអ៊ុំអីអត់ដូចជាម្ដាយរបស់អ៊ុំអីហាសដែរធ្លាប់បង្រៀនពីជំនាញអីធ្វើអីមួយទៅអ៊ុំអត់?

ខ៖ ដូចអត់មានអីកាលណុងជំនាន់ប៉ុលពតណុងអាលែងខ្ញុំនៅតូចៗដែរជំនាន់..។

ក៖ អូ៎!

ខ៖ គាត់ស្លាប់ទៅខ្ញុំតូចៗដែរ។

ក៖ ចឹងអ៊ុំអត់ដឹងទេណោះអ៊ុំណោះ?

ខ៖ អត់ដឹង។

ក៖ អូ៎!

ខ៖ មានតែរៀនក៏មិនសូវបានរៀនដែរវាល់តែជំនាន់ប៉ុលពតវាល់តែរត់អូ៎ជំនាន់នេះវាល់តែរត់ហោស!

ក៖ បាទអ៊ុំបាទ!

ខ៖ វាល់តែរត់។

ក៖ ប៉ុន្តែលក្ខណៈដូចវេញវល្លិ៍ កូរស្ករធ្វើត្នោតអីរឺមួយក៏ធ្វើល្អីអីក៏អត់ដែរ?

ខ៖ អត់មានទេមានតែធ្វើស្រែហ្នឹងចំការហ្នឹង!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចឹងមានន័យថាគាត់អត់ដែរធ្វើខាងត្បាញខាងអីទេណោះអ៊ុំណោះ?

ខ៖ ត្បាញធ្វើត្បាញភួយត្បាញអីចឹងដែរ។

ក៖ អូ៎!

ខ៖ ខ្ញុំអីត្បាញក្ធួយត្បាញអីធ្វើក្ធួយធ្វើក្រម៉ាធ្វើអីចឹងដែរ។

ក៖ ចឹងមានន័យថាអ៊ុំធ្វើជាមួយគាត់ដែរទៅ?

ខ៖ ជាមួយគាត់ណុងមិនដែរបានធ្វើទេខ្ញុំនៅតូចៗជំនាន់ចល័តអាដែង។

ក៖ អូ៎!

ខ៖ នេះហោស!

ក៖ ចឹងអ៊ុំដែរ..?

ខ៖ ប៉ុលពតអត់ដែរធ្វើទេទាល់ចប់គាត់ស្លាប់បាត់អស់ទៅខ្ញុំនៅជាមួយជីដូន។

ក៖ អូ៎!

ខ៖ ទៅបានធ្វើក្ធួយជីដូនបង្រៀនធ្វើក្ធួយធ្វើក្រម៉ាធ្វើអីហ្នឹង!

ក៖ ចឹងមានន័យថាអើយាយរបស់អ៊ុំអត់ទាន់គាត់អត់ទាន់ស្លាប់ទេ?

ខ៖ ស្លាប់ហើយឥឡូវហ្នឹងហោសព្រោះម៉ែ..។

ក៖ ប៉ុន្តែកាលជំនាន់ប៉ុលពតហាស?

ខ៖ ជំនាន់ប៉ុលពតគាត់អត់ទាន់ស្លាប់ទេ។

ក៖ ឪពុកម្ដាយអ៊ុំស្លាប់មុន?

ខ៖ ស្លាប់មុន។

ក៖ អូ៎យល់ចុះអើឪពុកម្ដាយរបស់អ៊ុំគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ុំអត់ថាគាត់ធ្លាប់ធ្វើការងារអីគេខ្លះកាលនៅក្មេងៗពួកគាត់ហាស?

ខ៖ ចា៎!

ក៖ គាត់ធ្លាប់និយាយលេងជាមួយអ៊ុំរឺក៏ធ្លាប់ប្រាប់អី?

ខ៖ អត់មានដេរធ្វើអីផងដឹងក្ដីមកគាត់ធ្វើតែចំការហើយហ្នឹងស្រែហ្នឹងម៉ង។

ក៖ អូ៎!

ខ៖ អត់ដែរបានធ្វើជាងអីហ្នឹងគេធ្វើតែចំការហើយហ្នឹងស្រែ។

ក៖ បាទអ៊ំបាទ!

ខ៖ អស់ពីស្រែចំការដល់ខែធ្វើស្រែធ្វើស្រែដល់ខែធ្វើចំការធ្វើចំការ។

ក៖ អូ៎បាទអ៊ំចុះអើយាយតាខាងឪពុកឈ្មោះអីគេអ៊ំអ៊ំស្គាល់ឈ្មោះគាត់អត់?

ខ៖ ឈ្មោះដឹងឈ្មោះខាងឪពុកតាប៉ាល់ណុងប៉ុនអត់ដឹងជីដូនជីតាគាត់ឈ្មោះអី។

ក៖ អូ៎!

ខ៖ ឈ្មោះតាប៉ាល់ហើយចឹងដាក់តាប៉ាល់ហ្នឹង!

ក៖ បាទចុះអើយាយ?

ខ៖ យាយឈ្មោះយាយនាន។

ក៖ យាយនានហោស?

ខ៖ ចាំយាយនានហៅទូច។

ក៖ អូ៎ចុះអើយាយតាខាងម្ដាយអ៊ំស្គាល់ឈ្មោះគាត់អត់?

ខ៖ ខាងម្ដាយឈ្មោះតាលាង។

ក៖ តាលាងយាយអី?

ខ៖ យាយធួន។

ក៖ តាលាងយាយធួនអូ៎ចុះអើយាយតាខាងម្ដាយហ្នឹងយាយតាខាងឪពុកគាត់អ្នកស្រុកនៅណាអ៊ំអ៊ំដឹងអត់?

ខ៖ តាខាងម្ដាយនៅគគរចឹងហើយនៅគគរ។

ក៖ អូ៎នៅគគរ?

ខ៖ គគរឆ្លងទន្លេតិចកោះកុក។

ក៖ បាទៗស្គាល់?

ខ៖ នៅគគរ។

ក៖ ប៉ុន្តែយាយខាងឪពុកនៅណុងដែរ?

ខ៖ យាយតាខាងឪពុកនៅខាងកោះកុកណោះ។

ក៖ អូ៎ចឹងពួកគាត់នៅជិតគ្នាទាំងអស់ទេណោះអ៊ុំណោះ?

ខ៖ ចា៎!

ក៖ អូ៎បាទអ៊ុំចុះអ៊ុំគិតថាអ៊ុំមករស់នៅហ្នឹងអស់រយះពេលប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ មកនៅហ្នឹងហោស?

ក៖ បាទអ៊ុំ!

ខ៖ មកនៅទើបចូលឆ្នាំហ្នឹង!

ក៖ ចឹងមានន័យថាអត់ទាន់បានមួយឆ្នាំទេណោះអ៊ុំណោះ?

ខ៖ ចា៎អត់ទាន់បានមួយឆ្នាំទេ។

ក៖ នៅជាមួយកូន?

ខ៖ នៅជាមួយកូន។

ក៖ អូ៎បាទអ៊ុំបាទចុះអើអ៊ុំមានបងប្អូនកូនចៅណាដែរទៅរស់នៅក្រៅប្រទេសអីអត់អ៊ុំដូចនៅថៃធ្វើការរឺមួយក៏នៅកូរ៉េអីមានទេអ៊ុំ?

ខ៖ អត់មានទេ។

ក៖ មានតែនៅខ្មែរហ្នឹងទេណោះអ៊ុំ?

ខ៖ មានតែនៅខ្មែរមានតែនៅថៃមានតែប្អូនពៅមួយហ្នឹង!

ក៖ អូ៎!

ខ៖ ចុះទៅថៃចុះទៅឡើងហ្នឹង!

ក៖ ចុះឥឡូវគាត់..?

ខ៖ មកកូវ៉ីណាហ្នឹងមកស្រុកវិញហើយ!

ក៖ អូ៎ប៉ុន្តែនៅពេលចប់កូវ៉ីណាគាត់អាចទៅវិញទៅនៅថៃវិញ?

ខ៖ ដឹងអីដឹងទៅដឹងអត់ទៅមិនដែរបានទៅផ្ទះណុង..។

ក៖ ដោយសារផ្ទះគាត់នៅជាប់ព្រំប្រទល់ថៃមែនអត់?

ខ៖ ណុងហើយថានៅជិតនៅជិតណុង។

ក៖ អូ៎បាទអ៊ុំបាទចុះអើស្វាមីរបស់អ៊ុំឈ្មោះអីគេទៅអ៊ុំ?

ខ៖ ឈ្មោះអើជីឈុន។

ក៖ អូ៎ប៉ុន្តែអ៊ុំរៀបអាពាហ៍ពិពាហ៍អស់រយះពេលប៉ុន្មានឆ្នាំទៅ?

ខ៖ រៀបអាពាហ៍ពិពាហ៍ហ្នឹងបានជាងម្ភៃឆ្នាំម្ភៃប៉ុន្មានឆ្នាំទេនេះ។

ក៖ ចឹងកូនអ៊ុំកូនបងអាយុប៉ុន្មានទៅអ៊ុំ?

ខ៖ កូនបងអាយុអើមើលឆ្នាំជូតសាមជាងហើយសាមប៉ុន្មានសាមប្រាំមួយសាមប្រាំពីរហើយទេហ្នឹង!

ក៖ អូ៎ចូលសាមប៉ុណ្ណឹង?

ខ៖ ហ្នឹងហើយ!

ក៖ កូនអ៊ុំការអស់ហើយសាមសិបប្រាំពីរសាមសិបប្រាំបីឆ្នាំហើយណោះអ៊ុំណោះ?

ខ៖ ហ្នឹងហើយការការមើលការរួចមួយឆ្នាំមានកូនឆ្នាំជូតហ្នឹង!

ក៖ អ៊ំចឹងមានន័យថាអ៊ុំអត់ទំនេរពោះផងហោស?

ខ៖ ចាំការរួចមានម៉ង។

ក៖ អ៊ំលឿនប៉ុន្តែអ៊ុំការហ្នឹងការឆ្នាំណាអ៊ុំឆ្នាំប៉ែត្រជាងមែនរឺមួយក៏ឆ្នាំចិតជាង?

ខ៖ ឆ្នាំប៉ុន្មានទេខ្ញុំភ្លេចហើយ!

ក៖ ប៉ុន្តែគ្រាន់ថា..?

ខ៖ វាឆ្នាំជូតការឆ្នាំ..។

ក៖ ប៉ុន្តែប៉ុលពតរឺមួយក៏ប៉ុលពតហើយ?

ខ៖ ដាច់ប៉ុលពតហើយ!

ក៖ ដាច់ប៉ុន្មានឆ្នាំអ៊ុំដាច់ពីរបីឆ្នាំមែនអ៊ុំបានការ?

ខ៖ ដាច់ប៉ុន្មានឆ្នាំមើលអាលែងកូនអាយុសាមប្រាំពីរហើយ!

ក៖ សាមប្រាំពីរចឹងមានន័យថាដាច់បីបួនឆ្នាំ?

ខ៖ ណុងហើយ!

ក៖ ចឹងមានន័យថាអ៊ុំការឆ្នាំប៉ែត្របីអ៊ំបាទអ៊ុំ!

ខ៖ ណុងការណុងនៅចងដៃតិចៗហ្នឹងអ៊ំការគេចងដៃអង្ករចងដៃអីណុងកាលណុងហោស!

ក៖ អ៊ំបាទ!

ខ៖ ចងដៃអង្ករវេចអង្ករមួយធ្នក។

កៈ ចុះអ៊ុំគិតថា..?

ខៈ ស៊ីសំលជីឆាយអីហ្នឹងជំនាន់ការខ្ញុំហោស!

កៈ បាទអ៊ុំ!

ខៈ សំលប៉ុន្មានមុខហ្នឹង!

កៈ អ៊ុំមានកូនប៉ុន្មាននាក់ទៅអ៊ុំ?

ខៈ ខ្ញុំមានកូនបួននាក់។

កៈ បួននាក់ណោះអ៊ុំណោះ?

ខៈ ចាំស្រីបីប្រុសមួយ។

កៈ អូ៎កូនបងគាត់អ្នកនៅណាទៅ?

ខៈ កូនបងនៅផ្សារសំរោងយោងហោស!

កៈ អូ៎គាត់នៅខាងតាកែវហោស?

ខៈ ចាំ!

កៈ គាត់រកស៊ីអីគេនៅណុងអ៊ុំ?

ខៈ គាត់នៅអើវានៅលក់ប្រាក់លក់អីនៅជាមួយក្មួយនៅណុងហាស!

កៈ អូ៎!

ខៈ អើក្មួយណុងគេ..។

កៈ គាត់មានកូនចៅទៀតទៅណោះអ៊ុំ?

ខៈ ណុងហើយណុងនៅលីវទេបងគេណុង។

កៈ អូ៎គាត់អត់យកគ្រួសារផងហោស?

ខ៖ អត់យកគ្រួសារទេចេះហោសមកចេះមិនត្រូវៗចិត្ត។

ក៖ ទាល់ឥឡូវទៅណោះអ៊ុំ?

ខ៖ ចាំ!

ក៖ ចុះទៅពីរ?

ខ៖ ទីពីរនៅហៅពុកឫស្សីៗឆ្លងព្រែកតាម៉ាកទៅហៅពុកឫស្សីហៅខេត្តនេះខេត្តនោះ។

ក៖ អ៎ូនៅខេត្តកណ្តាល?

ខ៖ នៅខេត្តកណ្តាលចឹងនៅពុកឫស្សី។

ក៖ តែគាត់បានមានគ្រួសារ?

ខ៖ មានគ្រួសារទៅនៅណុង។

ក៖ ប៉ុន្តែគាត់រកស៊ីអីទៅអ៊ុំ?

ខ៖ រកស៊ីមុនធ្វើការរោងចក្រហ្នឹងដល់ពេលឥឡូវកូនខ្ញីគ្មានបានទៅធ្វើការស្អីប្តីនៅធ្វើការរោងចក្រ។

ក៖ អ៎ូ!

ខ៖ ចាំ!

ក៖ ដល់ពេលទីបីទៅកំពង់ចាមហ្នឹង?

ខ៖ ទីបីនៅកំពង់ចាមហ្នឹង!

ក៖ អ៎ូប៉ុន្តែអ៊ុំមកនៅជាមួយកូនពៅណោះអ៊ុំណោះ?

ខ៖ អត់កូនពៅទេកូនពៅប្រុស។

ក៖ អ៎ូចឹងទីបីគាត់ណោះ?

ខ៖ ចាំ!

ក៖ បងប្រុសអ៊ំបាទប៉ុន្តែពៅគេនៅណាទៅអ៊ុំ?

ខ៖ ពៅនៅគគរ។

ក៖ អ៊ំនៅកោះកុកហោស?

ខ៖ ចាំនៅឆ្លងគគរណុង។

ក៖ ប៉ុន្តែគាត់មានគ្រួសារដែរ?

ខ៖ មានគ្រួសារហើយ!

ក៖ អ៊ំបាទអ៊ុំបាទចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំប្រុសហ្នឹងដូចជាអ៊ុំចិត្តចង់រៀបដោយខ្លួនឯងរឺមួយក៏ពេលណុងឪពុកម្ដាយអ្នករៀបចំអោយយើង?

ខ៖ ជីដូនរៀបចំអោយ។

ក៖ ប៉ុន្តែយើងស្គាល់គ្នាពីមុននៅអ៊ុំ?

ខ៖ ចាំនៅផ្ទះមុខក្រោយចឹង។

ក៖ អ៊ំ!

ខ៖ ជួរមាត់ទន្លេខ្ញុំជួរមាត់អូរ។

ក៖ អ៊ំបាទ!

ខ៖ ចាំ!

ក៖ ប៉ុន្តែអើប្ដីរបស់អ៊ុំគាត់ធ្វើអីគេទៅអ៊ុំ?

ខ៖ ធ្វើស្រែធ្វើចំការហ្នឹង!

ក៖ អ៊ំ!

ខ៖ ដឹងក្ដីមកធ្វើតែស្រែធ្វើចំការ។

ក៖ ដល់ពេលចាប់ដៃជាមួយអ៊ុំក៏នៅធ្វើស្រែធ្វើចំការដែរ?

ខ៖ ចា៎ធ្វើស្រែចំការទាំងអស់គ្នា។

ក៖ អូ៎ប៉ុន្តែឥឡូវគាត់នៅបែកពីអ៊ុំ?

ខ៖ អត់បែកទេប៉ុននៅមើលគោនៅអីកោះណោះ។

ក៖ អូ៎!

ខ៖ ធ្វើរោងជិតដឹកគោមកហ្នឹងហើយ!

ក៖ អូ៎!

ខ៖ ខែទឹកដឹងហើយ!

ក៖ អូ៎!

ខ៖ ចា៎!

ក៖ ចុះគាត់នៅណោះនៅជាមួយកូនពៅ?

ខ៖ អត់កូនពៅទេនៅជាមួយក្មួយផ្ទះខ្ញុំប្រុងលក់ទៅហោស!

ក៖ អូ៎!

ខ៖ អត់រស់មកធ្វើអត់មានតែពីរនាក់ចឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ មានតែពីរនាក់ទៅកូនៗថាមិនបាច់នៅធ្វើផ្ទះនៅទេ។

ក៖ អោយនៅជាមួយគាត់ម៉ង?

ខ៖ អោយមកនៅជាមួយកូនម៉ងទៅ។

កៈ អ៊ូល្អ!

ខៈ បើលក់ផ្ទះណុងចោលទៅ។

កៈ បាទអ៊ុំចុះអ៊ុំកាលអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំប្រុសហ្នឹងដូចជាអ៊ុំប្រុសមានជាជូនថ្លៃទឹកដោះថ្លៃបណ្ណាការទៅអត់ជំនានណុង?

ខៈ អើជំនាន់ណុងជូនសំលដប់តុអោយសំលដប់តុ។

កៈ អ៊ូបានសំលដប់តុហោស?

ខៈ ចាំ!

កៈ ប៉ុនកាលជំនាន់ណុងយើងការម៉េចទៅអ៊ុំ?

ខៈ ចាំ!

កៈ ខុសពីយើងឥឡូវយើងការដូចគ្នាអ៊ុំ?

ខៈ ការមានកាត់ដក់មានអីដែរចឹងហាស!

កៈ អ៊ូប៉ុន្តែមានបុកល័ក្ខបុកអីដែរអ៊ុំហោស?

ខៈ អត់កាលណុងអត់បុកល័ក្ខទេ។

កៈ តែការប៉ុន្មានថ្ងៃទៅអ៊ុំ?

ខៈ ការមួយយប់មួយថ្ងៃ។

កៈ ដូចយើងដែរហោស?

ខៈ ចាំ!

កៈ អ៊ូប៉ុនមានសូត្រមន្តសូត្រអីដូចគ្នាចឹងទៅ?

ខៈ ចាំការថ្ងៃហ្នឹងទៅលេងអ្នកយប់ទៅសំពះនេះហ្នឹង!

កៈ ប៉ុន្តែជំនាន់ណុងគេការគេចងដៃអីទៅអ៊ុំគេចងដៃអង្គរហោសអ៊ុំ?

ខៈ កាលណុងខ្ញុំដូចចងដៃលុយហើយចំណែកខ្ញុំដើរស៊ីការចងដៃអង្គរដល់ពេលខ្ញុំការចង់ដៃលុយកាលណុង។

កៈ មានលុយមានអីដែរហោសអ៊ុំ?

ខៈ ចាំ!

កៈ អាលុយរូបគោយើងណោះអ៊ុំណោះ?

ខៈ អត់លុយរូបគោទេចងដៃកាលណុងដូចតិច។

កៈ គេចាយកាក់អ៊ុំហោសជំនាន់ណុង?

ខៈ ចាំ!

កៈ ជំនាន់ណុងគេចាយកាក់នៅឡើយ?

ខៈ ណុងហើយគេចាយលុយប្រាំកាក់ប្រាំអីក្រដាស់មួយរៀលក្រដាស់អីចឹង។

កៈ អ៊ូបាទបាទចុះអើអ៊ុំគិតថាចឹងដូចជាអ៊ុំធ្លាប់មានអនុស្សាវរីយ៍ពីមុនទេអ៊ុំពេលមុនការធ្លាប់មានអនុស្សាវរីយ៍ជាមួយអ៊ុំប្រុសទេ យើងដោយសារយើងស្គាល់គ្នាពីមុនហាសមុនការណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ ចឹងយើងធ្លាប់ដើរលេងរឺមួយក៏ធ្វើអីដូចក្មេងៗសម័យហ្នឹងឥឡូវគ្រាន់គេភ្ជាប់ពាក្យចឹងគេដើរលេង..?

ខៈ ដើរលេងណុងអត់ទេ។

កៈ អត់ទេណោះ?

ខៈ ឃើញតែមុខគ្នាហ្នឹងគេចបាត់ហើយ!

កៈ អ៊ូ!

ខៈ ឃើញដើរទៅដល់នេះហ្នឹងណោះចូលផ្លូកនេះហោសមិនដែរអោយចូលជួបមុខទេ។

កៈ អ៊ូចឹងហោសអ៊ុំ?

ខៈ ចាំ!

កៈ អ៊ូបាទអ៊ុំប៉ុន្តែអ៊ុំកាលជំនាន់ណុងអ៊ុំធ្លាប់បានរៀនសូត្រអត់អ៊ុំធ្លាប់បានរៀនខ្មែរអត់?

ខៈ រៀនបានថ្នាក់ទីដប់ពីរហ្នឹង!

កៈ បាទអ៊ុំបាទ!

ខៈ ថ្នាក់ទីដប់ពីរកាលណុងថ្នាក់ទីមួយទីពីរហ្នឹងចាំដប់ពីរហ្នឹង!

កៈ បាទអ៊ុំបាទ!

ខៈ ចាំ!

កៈ គេរាប់បញ្រ្ចាស់វិញណោះអ៊ុំណោះ?

ខៈ ចាំថ្នាក់ទីដប់មួយទីដប់មួយទីដប់ពីរទីប្រាំបួនទីប្រាំបីអីចុះក្រោមមក។

កៈ បាទប៉ុន្តែអ៊ុំបានរៀនថ្នាក់ទីដប់ពីរ?

ខៈ ចាំរៀនវាល់តែថាជំនាន់លុនណុលណុងវាល់តែគេបន្តក់ចូលមកបន្តក់អីទៅបរទេះរត់ទៅ ប៉ុនទៅដល់ទៅគ្រប់កន្លែង។

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាជំនាន់ណុងអ៊ុំធ្លាប់បានរៀនបារាំងអត់អ៊ុំ?

ខៈ អត់ចេះអីទេមានបារាំងមានអីទេ។

កៈ អ៊ុំអត់ដែរបានរៀនទេ?

ខៈ អត់បានរៀនរៀនដូចក្មេងឥឡូវថ្នាក់ទីមួយទីពីរហ្នឹង!

កៈ អ៊ំបាទអ៊ុំប៉ុន្តែកាលអ៊ុំរៀនហ្នឹងរៀននៅណាគេគរហ្នឹងហោស?

ខៈ នៅកោះកុក។

កៈ នៅកោះកុកមែន?

ខៈ នៅសាលាកោះកុក។

កៈ អ៊ំបាទអ៊ុំប៉ុន្តែអ៊ុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់អ៊ុំកាលជំនាន់នៅរៀនហាស?

ខៈ មិត្តភក្តិប៉ុន..។

កៈ ឥឡូវបែកគ្នា?

ខៈ បែកគ្នាអស់ហើយ!

កៈ អ៊ំមានច្រើនដែរណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ អ៊ុំធ្លាប់មានអនុស្សាវរីយ៍មិត្តភក្តិអត់អ៊ុំកាលនៅរៀនហាសធ្លាប់លក្ខណៈដើរលេងជាមួយគ្នាទៅស្រែចាប់ត្រីចាប់ក្តាមអីហ្នឹង?

ខៈ ដូចមិនសូវដែរមានដើរលេងទៅចាប់ក្តាមបើថាទៅចាប់ក្តាមនៅក្នុងអូរក្នុងអីបងប្អូនអីហ្នឹង!

កៈ ហ្នឹងដែរណោះ?

ខៈ ចាំមិត្តភក្តិទៅចាប់ក្តាម។

កៈ អ៊ំបាទអ៊ុំបាទ!

ខៈ ជាមួយតែបងប្អូនណុងហ្នឹង!

កៈ ភាគច្រើនអ៊ុំដើរជាមួយបងប្អូនណោះ?

ខៈ ចាំ!

កៈ អូ៎ចុះអ៊ុំគិតថាចឹងស្រែចំការអ៊ុំធ្លាប់ធ្វើទេអ៊ុំ?

ខៈ ធ្លាប់ធ្វើ។

កៈ អូ៎ជាពិសេសអ៊ុំធ្វើអីគេធ្វើ..?

ខៈ ធ្វើ..។

កៈ ស្រែហោស?

ខៈ ដំណាំដាំអើធ្វើស្នូងស្រូវស្នូងអីជំនាន់ដូចថាយើងធ្វើចំការធ្វើស្រែហ្នឹងកាលណុងយើងធ្លាប់ស្នូងធ្លាប់ដកអីចឹងហាស។

កៈ បាទអ៊ុំ!

ខៈ ដល់ពេលធ្វើចំការមានដាំថ្នាំដាំពោត។

កៈ អូ៎!

ខៈ ដាំដំឡូង។

កៈ ចឹង..?

ខៈ សណ្តែក ល្ង។

កៈ ចឹងមានន័យថាទាំងស្រែទាំងចំការអ៊ុំធ្លាប់ធ្វើទាំងអស់?

ខៈ ចា៎!

កៈ អូ៎!

ខៈ ធ្វើទាំងអស់ខ្ញុំហោសប្រវត្តិ។

កៈ កាលណុងកាលនៅតូចៗណោះអ៊ុំណោះ?

ខៈ ចា៎ដឹងក្តីធំហើយមានប្តីហើយក៏ទៅតែចំការ។

ក៖ នៅតែធ្វើចំការថ្នាំចំការល្ហូចឹងទៅ?

ខ៖ ចា៎ជាពិសេសអាលែងដូចថាមានប្តីហើយនៅធ្វើជាប់ម៉ងបើនៅរៀងជំទង់ដើរធ្វើចល័តធ្វើអីហ្នឹងមានធ្វើអី។

ក៖ អូ៎!

ខ៖ ដើរតែធ្វើទៅវែកដីវែកអី។

ក៖ បាទអ៊ុំបាទប៉ុន្តែទាល់តឡូវអ៊ុំឈប់ហើយណោះអ៊ុំណោះ?

ខ៖ ឈប់ហើយ!

ក៖ ដោយសារកូនអោយនៅផ្ទះ?

ខ៖ ចា៎!

ក៖ បាទអ៊ុំចុះអើអ៊ុំទាក់ទងពីស្រែភាគច្រើនអ៊ុំធ្វើស្រែអីគេអ៊ុំស្រែប្រាំងស្រែវស្សា?

ខ៖ ស្រែវស្សា។

ក៖ ស្រែវស្សាហោស?

ខ៖ ជំនាន់ខ្ញុំធ្វើខ្ញុំធ្វើស្រែវស្សាស្រែប្រាំងក៏ធ្វើដែរ។

ក៖ ចឹងអ៊ុំធ្វើពីររដូវម៉ងហោស?

ខ៖ ចា៎ជំនាន់..។

ក៖ ចឹងលុយច្រើនហើយចឹង?

ខ៖ ចា៎!

ក៖ លុយច្រើនហើយ?

ខ៖ មានសូវលុយច្រើនបានតែត្រឹមម៉ា..។

កៈ ទុកហូប?

ខៈ ទុកហូបម៉ាគ្រប់គ្រាន់ហ្នឹង!

កៈ អ៊ូ!

ខៈ ម៉ាគ្រប់គ្រាន់។

កៈ បាទអ៊ីប៉ុន្តែអ៊ុំដូចជាចិញ្ចឹមសត្វធ្វើអាជីវកម្មធ្លាប់ធ្វើទេអ៊ុំ?

ខៈ មានតែចិញ្ចឹមជ្រូកចិញ្ចឹមគោ។

កៈ មាន់ទាអត់ដែរទេ?

ខៈ មាន់ទា។

កៈ អ៊ូចឹងអ៊ុំចិញ្ចឹមទាំងអស់ណោះ?

ខៈ ទាំងអស់។

កៈ ជាកសិដ្ឋានជាក្រុមគ្រួសារទុកដាក់លក់អ៊ុំ?

ខៈ ចិញ្ចឹមក្នុងដូចថាមិនចិញ្ចឹមអាលែងកសិដ្ឋានអាលែងនៅក្នុងផ្ទះហ្នឹងមេពីរបីអីចឹងទៅ..។

កៈ ប៉ុន្តែមែន..?

ខៈ គោពីរអីចឹងទៅ។

កៈ ប៉ុន្តែមែនទុកលក់ណាអ៊ុំណោះគ្រាន់តែទុកហូប?

ខៈ លក់ខ្លះទៅ។

កៈ អ៊ូទុកលក់ដែរហោស?

ខៈ ហូបខ្លះទៅ។

កៈ អ៊ូចុះទាក់ទងហ្នឹងលក់ដូរអ៊ុំធ្លាប់លក់ដូរអត់អ៊ុំ?

ខ៖ លក់ដូរអី?

ក៖ លក្ខណៈលក់អីក៏ដោយលក់អន្សមលក់អីផ្សេងៗចឹងហាសណាស់?

ខ៖ ចាំ!

ក៖ អ៊ុំដែរលក់អត់?

ខ៖ មិនសូវបានលក់ទេ។

ក៖ អ៊ុំអត់ដែរលក់ដែរហោស?

ខ៖ ចាំបើថាយូរៗទៅចង់មានចេកទៅអាំងអន្សមលក់ម្តងទៅលក់ទៅ។

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ធ្វើបាញ់អ្វូអីលក់ខ្លះទៅមិនយូរម្តងចង់ស៊ីអីទៅធ្វើខ្លះទៅហូបខ្លះទៅ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំអត់មាន។

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះតាំងពីក្មេងរហូតមកដល់ឥឡូវអ៊ុំពីក្មេងអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះអ៊ុំធ្លាប់ធ្វើស្រែចំការ?

ខ៖ ធ្វើស្រែចំការត្បាញ។

ក៖ ត្បាញ?

ខ៖ ត្បាញភួយត្បាញក្រម៉ាអី។

ក៖ អូ៎អាហ្នឹងការងារដែរអ៊ុំធ្វើពីតូចណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ ប៉ុន្តែអើ..?

ខ៖ ធ្វើពេលមានប្តីមកហ្នឹងហាសពីតូចមកអើជំនាន់ដូចថាចប់សង្គ្រាមហើយនៅជាមួយជីដូនហ្នឹងមានតែត្បាញភួយ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ត្បាញក្រម៉ា។

ក៖ បាទអ៊ុំបាទ!

ខ៖ ទាល់តែទើបតែឈប់ទើបឈប់ស្មាៗហ្នឹងទើបឈប់អាលែងគេចូលឆ្នាំទាល់មកថ្ងៃណោះហ្នឹងឈប់ត្បាញហ្នឹង!

ក៖ អូ៎!

ខ៖ ត្បាញរហូត។

ក៖ ចឹងមានន័យថា..?

ខ៖ ត្បាញក្រម៉ា។

ក៖ ចឹងមានន័យថាអ៊ុំនៅត្បាញក្រម៉ារហូត?

ខ៖ ចាំ!

ក៖ អ៊ុំនៅតែមើលឃើញត្បាញទៅកីដូចអី?

ខ៖ កី។

ក៖ ប៉ុន្តែអ៊ុំអាចប្រាប់ពីរបៀបត្បាញក្រម៉ាបានទេអ៊ុំគេត្បាញគេធ្វើអីគេខ្លះគេមានអីគេខ្លះ?

ខ៖ មុន..។

ក៖ ឧបករណ៍វាហាស?

ខ៖ ឧបករណ៍វាមុនដំបូងយើងដូចថាបើជំនាន់នេះរវៃវេច។

ក៖ អូ៎អារវៃយកអំបោះហ្នឹងហោស?

ខ៖ យកក្របាសយកក្របាស។

ក៖ អូ៎បាទ!

ខ៖ យកមកបោះបោះទៅយកមកច្ពេចមកយកទៅវវៃយកទៅជាអំបោះយកមកធ្វើវវៃ្វចផុង ទៅច្រឡូកធ្វើភួយធ្វើអីហ្នឹងអាហ្នឹងហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ជំនាន់ធ្វើភួយ។

ក៖ អូ៎បាទ!

ខ៖ ដល់ពេលឥឡូវហ្នឹងធ្វើក្រម៉ាហ្នឹងអត់មានវវៃទេទិញអំបោះគេយកមកច្រឡូកយកមកជួល គេច្រឡូកជួលអីយកមកអោយបាយយកមកអោយបាយសិកខារទៅអន្ទងទៅបានកដាក់ កិត្បាញម៉ង។

ក៖ អូ៎បាទស្រួល?

ខ៖ ចា៎!

ក៖ ប៉ុន្តែឥឡូវគេមានម៉ាស៊ីនវាអ៊ុំណោះ?

ខ៖ ឥឡូវមានម៉ាស៊ីនបានតែអំបោះលីងឡុងទេក្រម៉ាអំបោះត្បាញធ្វើអត់កើតទេ។

ក៖ គេមានក្រម៉ាអំបោះក្រម៉ាលីងឡុងដែរមែនទេអ៊ុំ?

ខ៖ ក្រម៉ាអំបោះក្រម៉ាលីងឡុង។

ក៖ អូ៎!

ខ៖ ខ្ញុំជំនាន់នៅជុំជាមួយកូនជាមួយអីហ្នឹងសុទ្ធតែត្បាញក្រម៉ាធ្វើអោយមួយគីៗម្នាក់ត្បាញហ្នឹង ហាស!

ក៖ អូ៎!

ខ៖ ក្រម៉ាលីងឡុងក្រម៉ាអំបោះ។

ក៖ អូ៎ចឹងមានន័យថាអ៊ុំបង្រៀនទៅកូនចៅដែរ?

ខ៖ ហ្នឹងហើយបង្រៀនកូនចៅគ្រប់កូនហ្នឹង!

ក៖ ចឹងពួកគាត់ចេះទាំងអស់ម៉ង?

ខ៖ ចេះទាំងអស់កូននេះចេះបានបន្តិចទេ។

ក៖ អូ៎ចុះប៉ុន្តែកូនរបស់អ៊ុំនៅហ្នឹងគាត់ធ្វើអីគេគាត់រកស៊ីអីអត់?

ខ៖ គាត់ធ្វើជាងទងជាងផ្លាកទីនហ្នឹង!

ក៖ អូ៎គាត់ធ្វើនៅផ្សារហោស?

ខ៖ ធ្វើនៅផ្ទះហ្នឹង!

ក៖ អូ៎រាល់ថ្ងៃគាត់ធ្វើហោស?

ខ៖ ចាំធ្វើនៅលើហោស!

ក៖ ប៉ុន្តែនរណាគេត្រូវការ..?

ខ៖ ត្រូវការ..។

ក៖ យករបស់គាត់បានគាត់ធ្វើ?

ខ៖ ហ្នឹងហើយគេការងារគេអោយជាប់រាល់ថ្ងៃហ្នឹង!

ក៖ អូ៎!

ខ៖ ធ្វើអោយអ្នកផ្សារ។

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចាំព្រោះកូនស្រីទៅធ្វើការទៅដេរ។

កៈ អ៊ូទៅដេរនៅក្រុមហ៊ុន?

ខៈ កូរ៉េក្រុមហ៊ុននេះក្រុមហ៊ុនខ្មែរថៃនេះនៅកន្លែងឌីដុកនេះ។

កៈ អ៊ូអង្គការឌីដុកណោះអ៊ុំ?

ខៈ ចាំប្រាក់ខែបានមួយរយប៉ែត្រ។

កៈ អ៊ូល្អចុះអ៊ុំគិតថាចឹងទាក់ទងពីអើជីវិតរបស់អ៊ុំមានការផ្លាស់ប្ដូរអីគេខ្លះទៅអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវអ៊ុំ គិតថាមានការពិបាករឺមួយមានការស្រណុកអីខ្លះទៅអ៊ុំ?

ខៈ អើខ្ញុំគ្មានស្រណុកទេមានតែពិបាក។

កៈ ចឹងចុះកាលពីក្មេងអ៊ុំគិតថាជីវភាពម៉េចដែរកាលនៅជាមួយឪពុកម្ដាយរហូតទាល់ឥឡូវ?

ខៈ ជីវភាពដូចថាម៉ាគ្រប់ម៉ាគ្រាន់ហូបចុកអីហ្នឹងអត់មានខ្វះម៉ាធ្វើស្រែធ្វើចំការហ្នឹងម៉ាហូបចុករួចមួយឆ្នាំទល់មួយឆ្នាំ។

កៈ អ៊ូបាទអ៊ុំបាទ!

ខៈ ចាំចេះតែមានចឹងអត់សល់។

កៈ អ៊ូបាទអ៊ុំ!

ខៈ ចាំ!

កៈ ប៉ុន្តែដល់ពេលឥឡូវឥឡូវអត់អីទេ?

ខៈ ឥឡូវអត់អីទេមកនៅជាមួយកូនកូនចិញ្ចឹម។

កៈ អ៊ូបាទអ៊ុំបាទចុះអ៊ុំគិតថាអើម្ហូបអីដែរអ៊ុំចូលចិត្តហូបអត់?

ខៈ ខ្ញុំធម្មតាម្ហូបអីក៏ហូបបានដែរ។

កៈ អ៊ូចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវអើអ៊ុំធ្លាប់លេងល្បែងប្រជាប្រិយ៍អីទេអ៊ុំលក្ខណៈបោះអង្គុញ ចោលឈូងកាលនៅក្មេងៗ?

ខ៖ ណុងហើយមានលេងកាលនៅពីក្មេងមានលេងបោះអង្គុញ ចាប់ឈូងអីមើលល្បែងល្បែងលេងបៀរលេងអីខ្ញុំអត់ចេះទេ។

ក៖ អ៊ូប៉ុន្តែអាលេងអាហ្នឹងកាលអ៊ុំនៅក្មេងៗណោះអ៊ុំធ្លាប់ណោះ?

ខ៖ ចាំនៅក្មេងៗមិនទាន់ការ។

ក៖ តែសម័យហ្នឹងគេឈប់លេងហើយណោះ?

ខ៖ ឈប់ហើយចាស់ហើយ!

ក៖ ប៉ុន្តែចង់និយាយថាក្មេងសម័យឥឡូវគេលែងលេងហើយ?

ខ៖ សម័យឥឡូវគេលែងលេងហើយ!

ក៖ បាទអ៊ុំបាទ!

ខ៖ អើ!

ក៖ ចុះអ៊ុំចូលចិត្តច្រៀងរាំទេអ៊ុំ?

ខ៖ ខ្ញុំមិនសូវដែរច្រៀងរាំអីផង។

ក៖ អ៊ូ!

ខ៖ នៅជំនាន់នៅតូចដូចថាធ្វើចំការធ្វើស្រែអីចឹងខែចូលឆ្នាំអីចឹងចូលអីហ្នឹងដូចថាអាលែងឪពុករបស់ខ្ញុំគាត់កាច់ថ្នាំកាច់អីយកមកតំរៀបសកអីហ្នឹង ចូឡឆ្នាំចូឡអីហ្នឹងពេញតែម៉ងធ្វើថ្នាំហោសអត់បានដើរលេងទេ។

ក៖ អ៊ូបាទអ៊ុំបាទ!

ខ៖ ធ្វើពេញធ្វើថ្នាំម៉ង។

ក៖ បាទអ៊ុំចុះអ៊ុំគិតថាចឹងទាក់ទងពីអើល្ខោនយីកេអាយ៉ៃអីកាលនៅពីក្មេងអ៊ុំចូលចិត្តមើលចូលចិត្តស្ដាប់ទេអ៊ុំ?

ខ៖ ទៅមើលដែរតើជំនាន់ណុងទៅមើល..។

ក៖ អូ៎អ៊ុំចូលចិត្តមើលដែរហោស?

ខ៖ អោយតែគេលេងណាទៅកាត់ទៅមើលហើយ!

ក៖ អូ៎បាទអ៊ុំ!

ខ៖ ទៅជុំគ្នា។

ក៖ ចុះលក្ខណៈជាសុំសិល្ប៍អីឥឡូវអ៊ុំសុំសិល្ប៍នៅអ៊ុំ?

ខ៖ សុំសិល្ប៍ហើយ!

ក៖ អូ៎!

ខ៖ ចា៎!

ក៖ សិល្ប៍ប៉ុន្មានទៅឥឡូវអ៊ុំ?

ខ៖ សុំសិល្ប៍ប្រាំ។

ក៖ អូ៎ចុះអ៊ុំគិតថាអើទាក់ទងពីអ៊ុំមានបងប្អូនកូនចៅណាដែរចេះលេងឧបករណ៍ភ្លេងទេអ៊ុំលក្ខណៈថាភ្លេងខ្មែរ ភ្លេងសៀមអីចឹងហាសណាស់?

ខ៖ អត់មានផងកូនៗ។

ក៖ អត់មាននរណាគេចេះទេណេះ?

ខ៖ កូនបងថ្លៃគាត់លេងប៉ុនគាត់ឈប់ហើយ!

ក៖ គាត់លេងភ្លេងអីអ៊ុំ?

ខ៖ មើលលេងភ្លេងមើលដូចជាអត់ទេដូចថាគាត់ស្គាល់គេអ្នកលេងភ្លេងអីគេមកដេកអីនៅផ្ទះចឹងប៉ុនគាត់អត់លេងទេ។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចឹងគ្រាន់ថាគាត់រាប់អានជាមួយគេអ្នកលេងភ្លេង?

ខ៖ ចាំជាមួយគេអ្នកលេងភ្លេងអីទៅលេងភ្លេងអីដល់ម៉ោងនៅផ្ទះខ្ញុំហ្នឹងហាស!

ក៖ អូ៎!

ខ៖ ស្គាល់ហាស!

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ អ្នកស្រីចំរៀងអ្នកអីហ្នឹងគាត់ស្គាល់។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ប៉ុនគាត់អត់លេង។

ក៖ អូ៎ចុះផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវកាលអ៊ុំនៅជាមួយឪពុកម្ដាយផ្ទះអ៊ុំម៉េចទៅ?

ខ៖ ផ្ទះហោសមានផ្ទះក្បឿងពីរខ្នង។

ក៖ អូ៎ប៉ុន្តែកាលណុងនៅកោះកុកណេះអ៊ុំ?

ខ៖ ចាំនៅកោះកុក។

ក៖ អូ៎ដល់ពេលអ៊ុំមានគ្រួសារអ៊ុំមានកូនចៅផ្ទះអ៊ុំនៅកោះកុកហ្នឹងផ្ទះម៉េចអ៊ុំ?

ខ៖ ផ្ទះណុងដូចថាផ្ទះកេរ្តិ៍របស់អើអាលែងជីដូនចឹងហាស!

ក៖ បាទ!

ខ៖ ដល់ពេលខ្ញុំនៅថៃជីដូនចឹងទៅឪពុកមាណុងប្រគល់អោយ។

ក៖ អូ៎!

ខ៖ ប្រគល់អោយពីរនាក់បងប្អូនណុងប៉ាល់សុខឿនហ្នឹង!

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំរួចដល់ពេលឥឡូវហ្នឹងខ្ញុំលក់ដូចថាផ្ទះជំនាន់ណុងវាចាស់ហើយផ្ទះអាលែងសសរទាបជញ្ជាំងទាបហោស!

ក៖ បាទអ៊ុំបាទ!

ខ៖ ពីរម៉ែត្រកន្លះហោស!

ក៖ អូ៎!

ខ៖ ដល់ពេលឥឡូវគេទៅលក់ទៅមកនៅជាមួយកូន។

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាចឹងផ្ទះរបស់អ៊ុំដែរអ៊ុំនៅពីមុនហ្នឹងនរណាគេអ្នកសាងសងជួសជុលវាទៅអ៊ុំ?

ខ៖ សាងសងជួសជុលអាលែងខ្មោចពុកខ្ញុំហ្នឹង!

ក៖ អូ៎គាត់ចេះធ្វើផ្ទះហោស?

ខ៖ អត់ទេគាត់ដូចថាគាត់ជួលគេធ្វើគេអីចឹងហាស!

ក៖ បាទអ៊ុំចុះអ៊ុំមានគិតថាអ៊ុំមាននរណាគេមួយនៅក្នុងក្រុមគ្រួសារបងប្អូនរឺកូនចៅអ៊ុំចេះធ្វើផ្ទះអត់?

ខ៖ ចេះធ្វើផ្ទះដូចអត់មាន។

ក៖ អូ៎ចឹងអត់មានទេអ៊ុំណេះ?

ខ៖ ចាំ!

ក៖ បាទអ៊ុំ!

ខ៖ បើខ្មោចជីតាខាងម្ដាយគាត់ធ្វើវិហារ។

ក៖ អូ៎!

ខ៖ គាត់ជាងវិហារ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចា៎ជាងវិហារជាងទូកង៉។

ក៖ អូ៎ចុះអ៊ុំគិតថាអ៊ុំអាចប្រាប់ពីការលំបាករបស់អ៊ុំតាំងពីក្មេងបានទេពីមួយជំនាន់ទៅមួយជំនាន់អ៊ុំកើតទាន់ជំនាន់អ៊ីសារ៉ាក់?

ខ៖ កើតទាន់ជំនាន់ដូចថាកាលជំនាន់លុនណុលទំលាក់គ្រាប់បែកគ្រាប់អីហ្នឹងហាស!

ក៖ អូ៎ប៉ុន្តែអ៊ីសារ៉ាក់អ៊ុំអត់ទាន់ទេ?

ខ៖ អ៊ីសារ៉ាក់។

ក៖ អ៊ីសារ៉ាក់ឆ្នាំហាជាង?

ខ៖ អត់ទាន់ទេ។

ក៖ លក្ខណ:ឃាតកុងអីក៏អត់ទាន់ដែរ?

ខ៖ ឃាតកុងហ្នឹងហាសជំនាន់ឃាតកុងហ្នឹងអាលែងនៅតែក្នុងរណ្ដៅហ្នឹង!

ក៖ ហ្នឹងណោះអ៊ុំណោះ?

ខ៖ ចា៎!

ក៖ អ៊ុំគិតថា..?

ខ៖ គ្រាប់បន្តក់គ្រាប់អីហ្នឹង!

ក៖ បាទ!

ខ៖ ផ្លោងមកនៅក្នុងរណ្ដៅលីតែរើមករត់ចូលរណ្ដៅដេកទាំងក្នុងរណ្ដៅទៀតហោស!

ក៖ អូ៎!

ខ៖ ជំនាន់យាគកុងហ្នឹងហោស!

ក៖ បាទអ៊ុំប៉ុន្តែអ៊ុំ..?

ខ៖ នៅតូចៗទៅដើរ..។

ក៖ យាគកុងយួនធ្មេញខ្មៅហ្នឹងអ៊ុំណោះ?

ខ៖ ដឹងយួនអើយាគកុងកាលណុង..។

ក៖ អ៊ុំដែរឃើញយាគកុងអត់កាលណុងជំនាន់ណុង?

ខ៖ យាគកុងខាងរំដោះហ្នឹងហោស!

ក៖ អត់ទេយាគកុងអ្នកដែរដូចជាធ្វើបាញ់គ្រាប់ផ្លោងទៅមកៗអីចឹងយួនយាគកុងយួនយាគកុងហោស?

ខ៖ ចា៎!

ក៖ អ៊ុំអត់ដែរឃើញទេហោសអ៊ុំ?

ខ៖ នៅតូចៗដែរដូចភ្លេចដែរ។

ក៖ អូ៎យាគកុងកាលជំនាន់ណុងហោស?

ខ៖ មានតែពួកអាយួនចូលចឹងទៅមានដែរតើជំនាន់ណុងខ្ញុំនៅចល័តហាសគេនៅចល័តនៅអីនេះនៅអីចល័តស្ទីលើទំនប់លើកត្រួយចេកហោសណុងហើយ ចូលមកយួនចូលមកគេជំលាសគេអោយទៅផ្ទះវិញហោស!

ក៖ អូ៎បាទ!

ខ៖ ដើរកាត់ណុងហើយយួន។

ក៖ ប៉ុន្តែអ៊ុំគិតថាជំនាន់លុនណុលដូចជាមានគេបន្ទុះគ្រាប់ផ្លោងមែនទេអ៊ុំ?

ខ៖ ចាំបើជំនាន់លុនណុលបន្ទុះគ្រាប់ផ្លោងរត់..។

ក៖ ប៉ុន្តែ..?

ខ៖ ទៅដេកតែក្នុងរណ្ដៅ។

ក៖ ប៉ុន្តែអ៊ុំអីផ្ទះអ៊ុំអីអត់អីទេ?

ខ៖ ផ្ទះហោសនេះតូចផ្ទះហ្នឹងត្រូវគេទំលាក់គ្រាប់បែកហ្នឹងគេផ្លោងគ្រាប់បន្តក់ទៅហ្នឹងចំរៀនបានផ្ទះជិតណុងហាស!

ក៖ អូ៎!

ខ៖ នៅជិតផ្ទះខ្ញុំហ្នឹងហាស!

ក៖ បាទ!

ខ៖ ទាំងទូទាំងអីនេះត្រូវអីទូហ្នឹងទើបយកមកកែកូនយកកែ។

ក៖ អូ៎!

ខ៖ ត្រូវគ្រាប់ផ្លោង។

ក៖ អូ៎បាទអ៊ុំប៉ុន្តែអ៊ុំគិតថាអើនៅជិតខាងអីអត់មានគេទំលាក់គ្រាប់ត្រូវផ្ទះត្រូវអី?

ខ៖ ត្រូវដែរតើ!

ក៖ មានអ្នកស្លាប់អីណាហីអ៊ុំហេស មានអ្នកស្លាប់ដោយសារបន្តក់គ្រាប់អីត្រូវអត់?

ខ៖ ទីណុងដូចជុំវិញផ្ទះខ្ញុំហ្នឹងដូចអត់មានត្រូវងាប់។

ក៖ ប៉ុន្តែគ្រាន់ឆេះផ្ទះឆេះអីមាន?

ខ៖ ត្រូវបែកបាក់ផ្ទះមាន។

កៈ អ៊ូ!

ខៈ គោមានតែគោងាប់ច្រើន។

កៈ អ៊ូធ្លាក់ត្រូវគោហោសអ៊ុំ?

ខៈ ហ្នឹងហើយជំនាន់អាកន្ទុំរុយអាដៃកន្ធរមកក្រឡឹងចឹងទៅងើបទៅវិញលែងទំលាក់គ្រាប់ហ្នឹង ងាប់គោរាយគេថាអាល្វៗធ្វើនាំគ្នាធ្វើល្វនេះថាឃាតកុង។

កៈ អ៊ូ!

ខៈ ទ័ពលុនណុលថាឃាតកុង។

កៈ ប៉ុន្តែចុះអើត្រង់សេយើងធ្វើនៅណាអ៊ុំកាលធ្វើនៅក្រោមផ្ទះ

ខៈ ធ្វើរណ្ដៅជីកឡើងសុះដី។

កៈ ប៉ុន្តែមែនគេធ្វើនៅក្រោមផ្ទះណាអ៊ុំណោះ?

ខៈ ធ្វើនៅក្រោមផ្ទះរណ្ដៅប៉ុន្មានហោសមួយគំនុកមួយជីកមួយឡើងសុះដីហោស!

កៈ អ្នកជិតខាងជីកចឹងដែរទៅ?

ខៈ ជីកដូចគ្នា។

កៈ រួចចុះអើយើងធ្វើការធម្មតាណោះអ៊ុំធ្វើស្រែធ្វើចំការធម្មតា?

ខៈ ធ្វើចំការធម្មតា។

កៈ ដល់ពេល..?

ខៈ ជូនណាទៅគាស់ជំឡូងអីគ្រាប់បន្តក់ទៅនាំគ្នាក្រាបនៅចំការជំឡូង។

កៈ ប៉ុន្តែគ្រាន់ថាអើដល់បេលយប់បានយើងរត់ចូលត្រង់សេពេលថ្ងៃក៏ចូលដែរអោយតែលឺមក អត់ទៅណាចាំតែរត់ចូលក្នុងត្រង់សេហ្នឹងម៉ង។

កៈ អ៊ូចឹងគ្មានបានធ្វើការអីទេអ៊ុំណោះ?

ខ៖ មិនសូវបានធ្វើការអីទេកាលណុងសំបូរអីហូបហាសណាស់ត្រីសាច់អីសំបូរ។

ក៖ អូ៎!

ខ៖ អូរមានអូរ។

ក៖ ចឹងយើងទៅធ្វើបាយធ្វើម្ហូបអីទៅធ្វើក្នុងត្រង់សេម៉ងហោស?

ខ៖ អត់ទេធ្វើនៅលើជិតមាត់រណ្ដៅត្រង់សេ។

ក៖ អូ៎មើលតែសភាពការណ៍មិនស្រួលក៏រត់ទៅ?

ខ៖ មិនស្រួលក៏រត់ចូលទៅជូនណាទៅនេះទៅដេកមួយយប់ទាល់ភ្លឺក្នុងត្រង់សេដាក់គ្រែដាក់អីទៅ។

ក៖ ដល់ពេលមើលតែស្រួលយើងឡើងមកលើវិញ?

ខ៖ ចា៎!

ក៖ អូ៎ម៉្យាងដែរ?

ខ៖ កាលណុងនៅតូចៗ។

ក៖ ចឹង..?

ខ៖ ដឹងក្ដី។

ក៖ ជំនាន់ណុងដូចជាអត់សូវមាននរណាគេរកស៊ីអីលក់ដូរអី?

ខ៖ មិនសូវរកស៊ីលក់ដូរអីដែរហ្នឹងសុទ្ធត្រូវតែ..។

ក៖ ដោយសារគេខ្លាចគ្រាប់គ្នាដែរ?

ខ៖ ចា៎!

ក៖ អូ៎បាទអ៊ុំចុះអ៊ុំគិតថាបន្ទាប់ពីជំនាន់លុនណុលអ៊ុំចូលជំនាន់អីជំនាន់ប៉ុលពតមានជំនាន់អីផ្សេងទៀតអត់អ៊ុំ?

ខ៖ មានតែជំនាន់ប៉ុលពតហ្នឹងមានជំនាន់ប៉ុលពតរួចចប់ហើយហ្នឹង!

ក៖ អូ៎បាទអ៊ុំ!

ខ៖ ជំនាន់ប៉ុលពតរួចមិនលែងសម្តេចនេះហ្នឹង!

ក៖ អូ៎ចុះអ៊ុំគិតថាជំនាន់ប៉ុលពតអើនៅណាអ៊ុំនៅកោះកុកហ្នឹងដដែរ..?

ខ៖ នៅកោះកុក។

ក៖ ឬគេជំលាសទៅណា?

ខ៖ កោះកុកនៅដូចថាគ្រាប់បន្តក់ច្រើនអីចឹងទៅជំលាសអោយទៅនៅទួលស្រែទួលអីបួនប្រាំថ្ងៃអីចឹងទៅបានចូលស្រុកមកវិញជំលាសមកនៅខាងព្រែកជីកខាងមកទៅគ្រប់កន្លែងហើយព្រែកជីកហើយហ្នឹងនេះបឹងអីគេហៅបឹងអីមកនៅរាប់ខែបឹងអីគេធ្វើចាក់ដីលុបទៅនេះ។

ក៖ បឹងស្នាយ?

ខ៖ បឹងស្នាយរួចទៅធ្វើដំណាំនៅហ្នឹងខ្មោចពុកខ្ញុំមកធ្វើដំណាំបន្លែធ្វើអីនៅហ្នឹង!

ក៖ អូ៎!

ខ៖ រាប់ខែដែរហ្នឹងហាស!

ក៖ បាទអ៊ុំបាទតែអ៊ុំគិតថាអើចឹងកាលចូលប៉ុលពតដំបូងឆ្នាំណាអ៊ុំឆ្នាំចិតប្រាំរឺមួយក៏ឆ្នាំចិតបី?

ខ៖ ឆ្នាំចិតប្រាំនេះហើយឆ្នាំចិតប្រាំគេចូលចិតបីហើយយ៉ាងចូលអាពត។

ក៖ ចាប់ផ្តើមចូលគេចាប់ផ្តើមជំលាសយើងហាស?

ខ៖ ណុងហើយបើចិតប្រាំគេជំលាសពីអ្នកកំពង់ចាមទៅវិញ។

ក៖ ប៉ុន្តែអ៊ុំអ៊ុំជំលាសដំបូងទៅណា?

ខ៖ ដំបូងហោសដំបូងមកនៅកោះគល់។

ក៖ កោះគល់?

ខ៖ មើលមកនៅដំបូងមកនៅព្រៃកជីក។

ក៖ អ៎ូ!

ខ៖ ព្រៃកជីកហើយបានមកនៅអីនេះបឹងស្នីនេះ។

ក៖ បឹងស្នាយ?

ខ៖ បឹងស្នាយ។

ក៖ ប៉ុន្តែកាលអ៊ុំនៅព្រៃកជីកគេអោយអ៊ុំធ្វើអីគេទៅប៉ុលពតហាសអ៊ុំ?

ខ៖ ធ្វើម៉ែខ្ញុំធ្វើក្រម៉ា។

ក៖ រួចចុះអ៊ុំ?

ខ៖ ខ្ញុំនៅតូចៗជួយគក់អំបោះគក់ជួយខារអំបោះខារអី។

ក៖ អ៎ូប៉ុន្តែអ៊ុំពេលណុងអ៊ុំអាយុដប់ពីរដប់បីឆ្នាំហើយហោសអ៊ុំ?

ខ៖ ចាំ!

ក៖ ប៉ុន្តែអ៊ុំគេអត់អោយទៅធ្វើកងកុមារកងអីទេអ៊ុំណេះ?

ខ៖ បើជំនាន់ប៉ុលពតបានធ្វើកុមារធ្វើកុមារធ្វើចល័តហ្នឹងហាស!

ក៖ អ៎ូប៉ុន្តែកាលណុងគេជំលាសទៅព្រៃកជីកហ្នឹងអ៊ុំណេះ?

ខ៖ ជំលាសព្រៃកជីកអត់ទាន់ធ្វើអីអត់ទាន់នេះទេនៅអាណុងនៅជុំឪពុកម៉ែនៅឡើយទេ។

ក៖ អ៎ូចុះឆ្នាំណាដែរគេជំលាសអោយអ៊ុំទៅធ្វើកងកុមារហើយធ្វើកងចល័តហាសអ៊ុំ?

ខ៖ កងចល័តហ្នឹងជំនាន់ប៉ុលពតហ្នឹងប៉ុលពតចិតឆ្នាំប៉ុន្មានទេ។

ក៖ ចិតប្រាំមួយណោះអ៊ុំណោះ?

ខ៖ ណុងហើយជំនាន់ប៉ុលពតហ្នឹងអាលែងអោយទៅធ្វើកុមារហ្នឹងកុមារធ្វើជីធ្វើអីហ្នឹងធ្វើទៅលើកទំនប់លើកអីហ្នឹង!

ក៖ នៅណាអ៊ុំ?

ខ៖ ធ្វើទៅលើកទំនប់នៅអឺស្ទឹងល្អៀកទៅហាមត្រួយចេកទៅហើយទៅ ណោះទៅលើកទំនប់នៅតំបន់ព្រៃឈរហោស!

ក៖ អូ៎!

ខ៖ រែកដីដាក់គល់។

ក៖ ពិបាកអត់អ៊ុំពេលណុង?

ខ៖ ពិបាករួចទៅដេកមានស្រួលអីពេលភ្លៀងមកដូចបាតបឹងណោះភ្លៀងមកទឹកត្រឹមៗជង្គង់ភ្លៀងរាំងទៅនាំគ្នាកាប់ដីកាប់ដីយកទៅចាក់ទៅលើហ្នឹងទៅនាំគ្នាក្រាលតង់ដេកទៅ។

ក៖ អូ៎បាទចុះបងប្អូនអ៊ុំជំលាសទៅផ្សេងៗទាំងអស់គ្នាមែនអ៊ុំ?

ខ៖ ប្អូនអាលែងប្អូនខ្ញុំនៅជាមួយជីដូន។

ក៖ អូ៎!

ខ៖ បងខ្ញុំនៅផ្សេងៗពីគ្នា។

ក៖ បាទអ៊ុំចុះអើចឹងរបបអាហារអីម៉េចដែរអ៊ុំកាលជំនាន់អ៊ុំនៅរែកដីរែក..?

ខ៖ អើជំនាន់ណុងហូបបាយគល់របបបាយម្ហូបស្មោរល្ពៅជាមួយត្រីឆ្អើរស្លអីត្រីឆ្អើរសុទ្ធតែដង្កូវ។

ក៖ អូ៎!

ខ៖ អាដង្កូវដោះពោមហោស!

ក៖ បាទអ៊ុំ!

ខ៖ ចាំជូនណាទៅអត់ចង់ហូបទៅសុំគេហូបបបរទៅគេបបរទៅគេអោយអំបិល។

ក៖ អ៊ូ!

ខ៖ បបរអោយមួយកន្ធរមកគេអោយអំបិល។

ក៖ បាទអ៊ុំបាទ!

ខ៖ មានម្ហូបចឹង។

ក៖ អ៊ូចុះប៉ុន្តែយើងហូបអត់ឆ្អែតចឹងយើងធ្វើម៉េចយើងហូបអត់ឆ្អែតដែរតើអ៊ុំណេះ?

ខ៖ ហូបអត់ឆ្អែតក៏ប៉ុននៅតែប៉ុណ្ណឹងដែរបើអត់។

ក៖ យើងអត់មានទៅលួចជីកក្ដួច ជីកដំឡូងអីដើម្បីហូបតណាហី?

ខ៖ អត់ទេអត់លួចផង។

ក៖ អត់ហ៊ានទេណេះអ៊ុំ?

ខ៖ អើអត់ហ៊ានដែរតើនៅកោះប្រាក់តែដំណាំខ្លួនឯងពេញដីមិនដឹងហ៊ានលួចផងខ្លាចគេយក
ទៅសំលាប់។

ក៖ អ៊ូបាទអ៊ុំចឹងចុះឈឺម៉េចទៅអ៊ុំ?

ខ៖ អត់ដែរឈឺជំនាន់ប៉ុលពត។

ក៖ អទ់ដែរឈឺទេណេះអ៊ុំ?

ខ៖ អត់ដែរឈឺទេមួយឆ្នាំៗគឺថាថ្ងៃណាខ្ញិលចឹងទៅធ្វើគេចជាឈឺម្ដងទៅ។

ក៖ អ៊ូ!

ខ៖ ចាំព្រោះឈឺ..។

ក៖ ចឹងឈឺគេអោយសំរាកហើយណេះ?

ខ៖ ចាំឈើគេអោយសំរាកហើយដល់ពេលឈើអត់ឈើសោះមួយជំនាន់ប៉ុលពត។

ក៖ អូ៎!

ខ៖ ហូបអត់គ្រប់អត់គ្រាន់ប៉ុនអត់ឈើ។

ក៖ ឈើក្បាលវិលមុខរាគអីអត់ដែរណោះ?

ខ៖ អត់សូវដែរអីផង។

ក៖ អូ៎ស្រួលណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ អូ៎រួចចុះអ៊ុំគិតថាចឹងចេញពីអាព្រៃឈរយើងទៅណាទៀតអត់អ៊ុំ?

ខ៖ ព្រៃឈរមកនេះដល់ពេលមកនេះមកមកនៅនេះអាលែងភ្នំនេះ។

ក៖ នៅភ្នំប្រុសភ្នំស្រីនេះហ្នឹងហោស?

ខ៖ ចាំមកនៅចល័តនៅណុងធ្វើស្រូវធ្វើអីចឹងស្ទូង។

ក៖ អូ៎!

ខ៖ ស្ទូងច្រូតស្រូវច្រូតបោកទៅនៅក្នុងហ្នឹងត្រង់នេះហ្នឹងត្រង់មុខលែងភ្នំហ្នឹង!

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំ!

ក៖ ប៉ុន្តែពិបាកអត់អ៊ុំ?

ខ៖ ពិបាកតើ!

ក៖ អើយើងនៅព្រៃឈរហ្នឹងយើងនៅភ្នំហ្នឹងណាពិបាកជាងអ៊ុំ?

ខ៖ ព្រៃឈរពិបាកប៉ុននៅភ្នំហ្នឹងមិនសូវពិបាកទេយើងដើរស្វែងដើរអីនៅព្រៃឈរហ្នឹងរែកដីផ្ទាក ខ្ពស់ហាស!

ក៖ អូ៎យើងជំលាសតែពីរកន្លែងហ្នឹងតើអ៊ុំហេសមានកន្លែងផ្សេងទៀត?

ខ៖ មាននៅត្រួយចេកនៅអូ៎បើថានៅពីមុនៗមកនៅដូចថានៅរៀងជំទើៗនៅតាមភូមិតាមអី ហ្នឹងចល័តទៅតាមភូមិ។

ក៖ អូ៎ចេះតែជំលាសហាសណេះអ៊ុំណេះ?

ខ៖ ចា៎!

ក៖ ចុះ…?

ខ៖ គេអោយយើងនៅ។

ក៖ ជំលាសចុងក្រោយនៅណាគេអោយយើងនៅភ្នំហ្នឹងណេះអ៊ុំណេះ?

ខ៖ ចា៎!

ក៖ អាគេរ៉ែដាច់ហាស?

ខ៖ ចា៎រ៉ែដាច់នៅដូចថាមើលនៅត្រួយចេកនៅត្រួយចេកទំនប់ត្រួយចេករួចមិនគេលែងយួន ចេញមកនោះ។

ក៖ អូ៎បាទ!

ខ៖ លែងហ៊ុនសែនហ្នឹងតែម៉ងហ្នឹង!

ក៖ បាទៗ!

ខ៖ បានចប់ហ្នឹង!

ក៖ អូ៎ចឹងចុះបងប្អូនរបស់អ៊ុំអីវីមួយក៏ម្តាយឪពុកអីម៉េចទៅអ៊ុំយាយអី?

ខ៖ យាយឥឡូវហ្នឹងហោស?

កៈ ចង់និយាយថាជំនាន់ប៉ុលពតហាស?

ខៈ អាលែងជំនាន់ប៉ុលពតពុកម៉ែខ្ញុំគាត់ដើរទៅស្ទូងពុកខ្ញុំដើរទៅភ្ជួរដីភ្ជួរស្រែ។

កៈ អូ៎ម៉េចបានគាត់ស្លាប់នៅជំនាន់ណុងអ៊ុំ?

ខៈ ជំនាន់ណុងដឹងគាត់មានជំងឺអាសន្នរោគអាសន្នរោគអាលែងម្ដាយហោស!

កៈ បាទ!

ខៈ អត់មានថ្នាំសង្កូវមើលទេគេព្យួរសារ៉ូមដប់អាលែង..។

កៈ បើទឹកដូងហ្នឹងណោះអ៊ុំណោះ?

ខៈ ដប់គេនេះហ្នឹងថ្នាំអីទេដប់ទឹកក្រូចហោស!

កៈ អូ៎!

ខៈ ប៉ូមចាក់ៗដាក់ព្យួរសារ៉ូមគាត់អត់ជាទេមើលជំនាន់ឥឡូវហ្នឹងអត់ងាប់ទេ។

កៈ អូ៎!

ខៈ កាលណុងអត់មានថ្នាំ។

កៈ បាទអ៊ុំបាទ!

ខៈ ទៅដេកនៅអង្គញដីអត់មានថ្នាំមានអីមានតែជំងឺអីក៏តែដប់ហ្នឹងជំងឺអីក៏តែដប់ហ្នឹងអត់គាត់ចុះៗទាល់តែស្លាប់។

កៈ ប៉ុន្តែគេមានអាថ្នាំអាចម៍ទន្សាយគេណោះអ៊ុំណោះថ្នាំខ្មៅៗហោស?

ខៈ កាលណុងខ្ញុំដឹងខ្ញុំទៅមើលប៉ុនឃើញតែព្យួរសារ៉ូមអាលែងដប់ហ្នឹងហើយហ្នឹងចាក់អាដប់ទឹកក្រូចប៉ុនៗកដៃ។

កៈ អូ៎ចុះម្ដាយអ៊ុំ?

ខៈ ម្ដាយហ្នឹងហាស!

កៈ ចុះឪពុកវិញ?

ខៈ ឪពុកនៅដេកពេទ្យនៅតាមភូមិនៅវត្តកោះប្រាក់។

កៈ ប៉ុន្តែគាត់ស្លាប់ដោយសារអីអុំ?

ខៈ ស្លាប់ដោយសារឈឺហ្នឹងគាត់ដូចថាគាត់ដូចហូពអត់គ្រប់គ្រាន់ហាសជំនាន់ប៉ុលពតគាត់ធ្វើការយ៉ាប់រួចទៅបបរទៅគាត់រៀងឈឺជំងឺហើមហាស!

កៈ បាទអុំបាទ!

ខៈ ហើមជើងហើមអីហ្នឹងហាស!

កៈ បាទអុំចឹងគាត់ស្លាប់ដោយសារចឹងទៅ?

ខៈ ថាអាស្លាប់ដូចអត់គ្រប់គ្រាន់ដោយសារបាយទឹកហ្នឹង!

កៈ អូ៎ប៉ុន្តែយាយ..?

ខៈ គាត់ធ្វើការ។

កៈ ប៉ុន្តែយាយអត់អីដែរ?

ខៈ យាយអត់អីយាយនៅបានរក្សាថៅទើបបានគាត់ស្លាប់ប៉ុន្មានឆ្នាំហ្នឹងដែរ។

កៈ អូ៎ប៉ុន្តែតាស្លាប់យូរហើយ?

ខៈ ចាំជំនាន់ប៉ុលពត។

កៈ ចង់និយាយថាអើឪពុកខាងឪពុកម្ដាយអុំទៀតស្លាប់យូរហើយ?

ខៈ ចាំ!

កៈ ប៉ុន្តែយាយដែរនៅហ្នឹងយាយខាងឪពុករឺមួយក៏យាយខាងម្ដាយ?

ខៈ យាយខាងឪពុកយាយខាងម្ដាយក៏គាត់ទើបគាត់ស្លាប់ជំនាន់ប៉ុលពត។

ក៖ អ៊ូ!

ខ៖ យាយខាងម្ដាយ។

ក៖ បាទអ៊ីបាទ!

ខ៖ ហ្នឹងស្លាប់គាត់ឈឺទៅគេបញ្ជូនអោយទៅដេកពេទ្យ។

ក៖ អ៊ូបាទអ៊ឺ!

ខ៖ នៅឈឺស្លាប់។

ក៖ ប៉ុន្តែបងប្អូនអ៊ីគាត់ភៀសទៅរៀងខ្លួនអស់ទៅ?

ខ៖ ចាំ!

ក៖ ដល់ពេលប៉ុលពតដាច់មកវិញបានវ៉ៃដាច់ទៅបានយើងមកជួបជុំគ្នា?

ខ៖ បងប្អូនខ្ញុំអត់អ្នកនៅហ្នឹងនៅជុំគ្នាអ្នកនៅរស់បីនាក់ហ្នឹងមើលមួយពីរបីបួននាក់ហ្នឹងនៅជុំគ្នាហាស!

ក៖ ពីរនាក់ដែរស្លាប់បងៗហ្នឹង..?

ខ៖ ណុងគាត់បែក។

ក៖ គាត់បែក?

ខ៖ មួយគេរើសធ្វើគេហៅធ្វើស្ទីនារី..។

ក៖ កងនារី?

ខ៖ កងនារីហោស!

ក៖ អ៊ូចុះអើធ្វើម៉េចបានយើងរកផ្ទះយើងឃើញអ៊ីដោយសារជំនាន់ណុងវាអត់មានទូរស័ព្ទអត់មានអីផងហ្នឹង?

ខ៖ ជំនាន់ណុង..។

កៈ គេប្រាប់យើងមែន?

ខៈ ចាំ!

កៈ គេប្រាប់យើងមែន?

ខៈ គេប្រាប់ម៉េច?

កៈ គេប្រាប់ថាបែកហើយបែកដាច់ប៉ុលពតហើយគេរ៉ៃរំដោះអីចឹងហាសណាស់ហើយ..?

ខៈ ចាំ!

កៈ យើងរត់មកផ្ទះវិញហាសគេប្រាប់យើងមែនរឺមួយក៏ដឹងដែរ?

ខៈ ខ្ញុំអត់មានរត់ទៅណាទេគ្រាន់តែរត់ថាអាទៅធ្វើចល័តហ្នឹងរត់មកផ្ទះអាលែងជីដូនខ្ញុំនៅផ្ទះហ្នឹងហាស!

កៈ អូ៎!

ខៈ ចាំប្អូនអីនៅផ្ទះ។

កៈ ចឹងមានន័យថាអ៊ុំស្គាល់ដែរហោសស្គាល់ផ្ទះដែរហោស?

ខៈ ស្គាល់តើខ្ញុំស្គាល់ផ្ទះ។

កៈ ហើយអ៊ុំរត់ទៅកោះកុកហ្នឹងម៉ងហោសអ៊ុំ?

ខៈ ចាំគេប្រលេញមកគ្នាច្រើនបានគ្នាច្រើនទៅកោះហ្នឹងម៉ង។

កៈ អូ៎!

ខៈ ទៅផ្ទះហ្នឹងម៉ង។

កៈ បាទអ៊ុំបាទ!

ខៈ មករកជីដូនហ្នឹងម៉ែឪស្លាប់អស់ហើយមករកជីដូន។

កៈ ដើរប៉ុន្មានថ្ងៃទៅអ៊ុំដល់?

ខៈ អូ៎បើដើរពីរនេះដើរតែមួយថ្ងៃល្ងាចដល់ផ្ទះហើយដើរទំនប់ត្រួយចេកហ្នឹងទៅហោស!

កៈ អូ៎ជិតដែរចឹងហោស?

ខៈ ចាំបើព្រៃឈរចេញមកដេកពីត្រឹមព្រៃឈរមកដើររហូតទាល់តែដល់អាលែងស្អីអាលែង ផ្សារជិតនៅភ្នំហ្នឹងដេកផ្លូវមួយយប់ដេកផ្លូវហ្នឹងមួយយប់បាន។

កៈ បាទអ៊ុំបាទព្រឹកឡើងដើរដល់?

ខៈ ដេកផ្លូវហ្នឹងមួយទៀតចាំ!

កៈ អូ៎បាទ!

ខៈ ចាំដើរទាល់តែយប់ហោសបានមកដេកផ្លូវហ្នឹង!

កៈ បាទអ៊ុំចុះនៅពេលដែរអ៊ុំដាច់ប៉ុលពតថ្មីៗពេលហ្នឹងអ៊ុំមានការលំបាកអីអ៊ុំ មានន័យថាពេល ដាច់ប៉ុលពតថ្មីៗយើងចាប់ផ្ដើមធ្វើស្រែរួមណោះអ៊ុំណោះ?

ខៈ ធ្វើស្រែសាមគ្គី។

កៈ បាទពេលហ្នឹងយើងមានការលំបាកអីអ៊ុំដោយសារគេអត់ទាន់មានចែកស្រែចែកអីអោយទេ ណោះ?

ខៈ ចាំអាហ្នឹងធ្វើដូចថាគេចែកជាស្រូវជាអីធ្វើទៅបានចែកគ្នាហូប។

កៈ បើយើងអត់ធ្វើទោអត់បានទៅ?

ខៈ ចាំ!

កៈ អូ៎ប៉ុន្តែពេលហ្នឹងយើងរកស៊ីអីទៅអ៊ុំអត់ទាន់រកស៊ីអីណាហីយើងនៅធ្វើស្រែ..?

ខៈ មានទាន់រកស៊ីអីទេនៅធ្វើតែស្រែហ្នឹង!

កៈ អូ៎ចុះយើងធ្វើចឹងអស់រយះពេលប៉ុន្មានឆ្នាំអ៊ុំបានគេចាប់ផ្ដើមចែកស្រែរៀងខ្លួនអោយ?

ខ៖ ទើបចែកស្មើរខ្ញុំមានគ្រួសារហើយនេះ។

ក៖ ចឹងឆ្នាំប៉ែត្រជាងប៉ែត្រពីរប៉ែត្របីហើយណោះអ៊ុំណោះ?

ខ៖ ចាំបានគេចែកស្រែអោយធ្វើសាមគ្គី។

ក៖ ចុះនៅពេលដែរនៅពេលដែរគេចែកស្រែចែកអីហើយអ៊ុំមានគ្រួសារទៅអ៊ុំមានការលំបាកអីអ៊ុំពេលចាប់ដៃជាមួយអ៊ុំប្រុសដំបូង?

ខ៖ មានពិបាកមានតែពិបាកធ្វើស្រែធ្វើចំការហ្នឹងចិញ្ចឹមកូន ចិញ្ចឹមកូនហ្នឹងកូនឈឺ។

ក៖ អូ៎!

ខ៖ កូនឈឺបានកូនពីរបីហ្នឹងឈឺមួយអាទិត្យឈឺម្តង។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ឈឺរកលុយបានអោយតែពេទ្យហ្នឹង!

ក៖ អូ៎បាទអ៊ុំបាទចុះទាក់ទងពីពេលណាដែរអ៊ុំគិតថារៀងធូរធារហើយចាយលុយហាសអ៊ុំហើយគិតថាគាត់ដើរហើយ?

ខ៖ ចាប់ពីណុងមកមានគ្រួសារណុងមានធ្វើស្រែធ្វើចំការហ្នឹង!

ក៖ ប្រហែលជាបានកូនប៉ុន្មានហើយអ៊ុំបានអ៊ុំគិតថាអ៊ុំដូចជាមានជីវភាពស្រួលបួលហើយរៀងសប្បាយជាងមុនចឹងហាសអ៊ុំ?

ខ៖ ដូចជាគ្មានស្រួលគ្មានសប្បាយទេរករហូតលែងធ្វើម៉ាបានតែម៉ាគ្រប់គ្រាន់ហ្នឹងទាល់តែ..។

ក៖ ចឹងមានន័យថាអ៊ុំតាំងពីក្មេងរហូតទាល់តែនៅនឿយរហូត?

ខ៖ នៅនឿយរហូតហ្នឹង!

ក៖ ទើបតែ..?

ខ៖ ទើបឈប់កន្លះឆ្នាំហ្នឹង!

កៈ ទើបតែរៀងស្រួលកន្លះឆ្នាំហ្នឹងទេណោះអ៊ុំ?

ខៈ ចាំ!

កៈ អូ៎!

ខៈ មានស្រួលមានឈឺហ្នឹង!

កៈ អូ៎បាទអ៊ុំ!

ខៈ ឈឺថៃលិចកើត។

កៈ បាទអ៊ុំបាទចុះចឹងអ៊ុំគិតថាដូចជាកាលពីក្មេងហាស?

ខៈ ចាំ!

កៈ អ៊ុំធ្លាប់មានគោលបំណងថាអ៊ុំធំឡើងអ៊ុំចង់ធ្វើអីមួយកាលអ៊ុំនៅរៀនហាស អ៊ុំធ្លាប់និយាយលេងជាមួយមិត្តភក្តិថាអូ៎ធំឡើងចង់ធ្វើពេទ្យ ធ្វើគ្រូបង្រៀន ធ្វើប៉ូលីសអី?

ខៈ ដូចអត់មានផងដូចបើអត់បានរៀនសូត្រផងហ្នឹង!

កៈ អត់មានគិតចង់ប៉ងអី?

ខៈ អត់មានគិតអីទេដូចឥឡូវហ្នឹងទេ។

កៈ អូ៎បាទអ៊ុំបាទ!

ខៈ ចាំ!

កៈ ចុះអ៊ុំមាន..?

ខៈ ព្រោះឪពុកម្តាយដូចគាត់អត់សូវមានបានតែម៉ាគ្រប់គ្រាន់។

កៈ អូ៎បាទអ៊ុំ!

ខៈ បានម៉ាហូបតែម៉ាគ្រប់ម៉ាគ្រាន់មួយឆ្នាំទាល់មួយឆ្នាំ។

កៈ បាទអ៊ុំចុះមានសំនួរចុងក្រោយមួយអ៊ុំបើសិនជាចង់អយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយហាស អ៊ុំមានពាក្យពេចន៍រឺមួយក៏អ៊ុំចង់ផ្ដាំផ្ញើររឺមួយក៏ពួកគាត់អីដើម្បីអោយពួកគាត់អាចអើលក្ខណៈថាខំប្រឹងរៀនរឺមួយក៏ធ្វើការងារល្អៗអីចឹងហាសណាស់អ៊ុំ?

ខៈ ចាំ!

កៈ មានពាក្យពេចន៍អីចង់ផ្ដែផ្ដាំទៅពួកគាត់អីអត់អ៊ុំ?

ខៈ ចង់ផ្ដាំដូចថារាល់ថ្ងៃហ្នឹងចង់ផ្ដាំដូចថាចៅហ្នឹងខំអោយវារៀនសូត្រទៅអោយវាចេះដឹងទៅអោយបានការងារធ្វើដូចពួកខ្ញុំអីចឹងវានឿយហត់ហាសណាស់។

កៈ បាទ!

ខៈ ចង់អោយកូនចៅហ្នឹងអោយបានរៀនទៅបានចេះដឹងធ្វើការធ្វើអីទៅបានប្រាក់ខែបានអីស៊ីចឹងទៅស្រួល។

កៈ បាទអ៊ុំបាទ!

ខៈ បើជំនាន់ពួកខ្ញុំហ្នឹងអើយពិបាកណាស់ធ្វើតែកាយតែដី។

កៈ អូ៎បាទអ៊ុំបាទ!

ខៈ ចាំ!

កៈ ចុះធ្លាប់មានទូន្មានព្រានប្រដៅទៅពួកគាត់ថាអើចៅៗអីណាហាមឃាត់កុំអោយជក់គ្រឿងញៀនអី?

ខៈ ចាំហាមតើ!

កៈ អ៊ុំធ្លាប់និយាយដែរណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ អូ៎!

ខៈ ចៅៗខំរៀនទៅទាន់បានចំណោះចេះដឹងមានការងារធ្វើទៅស្រួលខ្លួន។

កៈ បាទអ៊ុំបាទចុះអ៊ុំធ្លាប់ប្រាប់ពួកគាត់ថាអើអោយគាត់សំរេចនូវគោលបំណងអ៊ុំដែរអ៊ុំប៉ងថាអើអ៊ុំចង់ធ្វើអីមួយចង់អោយចៅៗធ្វើអ្វីដែរអ៊ុំគិតចង់អោយគាត់ធ្វើចឹងអ៊ុំ?

ខៈ ថាម៉េចស្តាប់អត់ទាន់។

កៈ លក្ខណ:ថាដូចជាអ៊ុំកាលពីក្មេងអ៊ុំធ្លាប់មានគោលបំណងថាអូ៎ធំឡើងអ៊ុំចង់ធ្វើអីមួយចឹងអ៊ុំធ្លាប់ប្រាប់ចៅៗថាអូ៎ឥឡូវសំរេចគោលបំណងយាយរឺមួយក៏តាអីដែរចង់អោយពួកគាត់ធ្វើអីដែរអ៊ុំអត់ធ្លាប់បានសំរេចចឹងហាស?

ខៈ ចា៎ខ្ញុំអត់សំរេចគិតអាលែងអត់ថាអោយរៀនតាមខ្ញុំថាអោយថាចង់អោយកូនចៅៗហ្នឹងអោយបានរៀនទៅបានធ្វើការធ្វើងារមានប្រាក់ខែមានអីស៊ីទៅអោយបានស្រួលខ្លួន។

កៈ អូ៎!

ខៈ ដូចពួកខ្ញុំចាស់ៗពីមុនមកវាពិបាកនឿយធ្វើតែការក្តៅ។

កៈ ត្រូវអ៊ុំត្រូវ!

ខៈ ត្រូវថ្ងៃត្រូវអីមានស្រណុកទេ។

កៈ អូ៎!

ខៈ រកស៊ីចិញ្ចឹមកូន។

កៈ បាទអ៊ុំចឹងអើអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្តាំផ្ញើរទៅគាត់ជៀសពីហ្នឹងអីទៀតអត់អ៊ុំ?

ខៈ ចា៎ដឹងថាម៉េចទៀតទៅ។

កៈ អត់មានអីទៀតទេណោះអ៊ុំណោះ?

ខៈ ចា៎!

កៈ ចុះចឹងអ៊ុំ..?

ខៈ គ្រាន់តែថាកុំអោយដូចថាដើររកអំពើអោយដើរតាមអំពើល្អកុំអោយជក់គ្រឿងញៀនជក់អីមើលទៅគេទៅពិបាកភ្នែក។

កៈ អូបាទអ៊ុំ!

ខៈ ចា៎!

កៈ ចឹងប្រហែលជាចុងក្រោយខ្ញុំសុំការអនុញ្ញាតិពីអ៊ុំដើម្បីដាក់សម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយចៅៗរឺមួយក៏កូនអ៊ុំបានស្គាល់បានដឹងបានទេអ៊ុំ ចង់និយាយថាខ្ញុំសុំការអនុញ្ញាតិណរីអ៊ុំដើម្បីដាក់ការសម្ភាសមួយហ្នឹងទៅក្នុងវេបសាយសាលាហាស?

ខៈ ចា៎!

កៈ អត់អីទេណេះអ៊ុំណេះ?

ខៈ ចា៎!

កៈ បាទចឹងចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសម្ភាសអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំដែរអ៊ុំបានរៀបរាប់ពីដើមរហូតមកចឹងហាសណាស់អ៊ុំ?

ខៈ ចា៎!

កៈ បាទអរគុណច្រើនអ៊ុំ៕